# សេចក្តីជូនដំណឹងមាតាឬបិតាស្តីអំពីការការការពារតាមនីតិវិធី

មាតាបិតាជាទីគោរពនិងរាប់អានៈ

មាតាបិតាទាំងអស់មានឱកាសទទួលសេចក្តីជូនដំណឹងស្តីអំពីការការពារ តាមនីតិវិធី (សេចក្តីជូនដំណឹង) ពីព្រោះ កូនប្រុស ឬ កូនស្រី (ជាសិស្ស) អ្នក ត្រូវបានគេបញ្ជូនដើម្បីធ្វើការវាយតម្លៃ ឬកូនអ្នកកំពុងតែទទួលសេវាកម្មអប់រំពិសេសនាពេលបច្ចុប្បន្ន។ ប្រសិនបើកូនរបស់អ្នកមានសិទ្ធិទទួលការអប់រំពិសេសនោះ សាលារៀនស្រុកត្រូវតែ ផ្តល់ការសិក្សាជាសាធារណៈសមរម្យដោយឥតគិតថ្លៃដែលជាទូទៅបានសម្តៅចំពោះអក្សរកាត់ FAPE។ ដើម្បីផ្តល់ FAPE សាលារៀនស្រុកត្រូវធ្វើការជាដៃគូរជាមួយអ្នក។ អ្នកនឹងក្លាយជាសមាជិករបស់ក្រុម IEP ដែលធ្វើការពិចារណាអំពីតម្រូវការសំរាប់កូនរបស់អ្នក និង ដើម្បីធ្វើការអភិវឌ្ឍន៍កម្មវិធីអប់រំ ឯកជន ឬ IEP សំរាប់កូនរបស់អ្នក[1] ។ IEP ត្រូវ ផ្តល់ការណែនាំដែលឆ្លើយតបទៅនិងឹតម្រូវការកូនអ្នក មានដូចជា សេវាកម្មគាំទ្រ ដ៏ពេញលេញដើម្បីធ្វើឲ្យកូនអ្នកមានការរីកចំរើនក្នុងការអប់រំ និង ទទួលបានចំណេះដឹង ជំនាញ និងអ្វីៗដែលចាំបាច់សំរាប់ការអភិវឌ្ឍន៍សង្គម និង ស្មារតីស្របទៅនឹងការរំពឹងទុកក្នុងការអភិវឌ្ឍន៍តាមកាលប្បវត្តិ ។ សេវាកម្ម អប់រំដែល ផ្តល់ជូនកូនអ្នកត្រូវចំណាយដោយថវិការសាធារណៈ អ្នកមិនត្រូវចំណាយថវិការផ្ទាល់ខ្លួនឡើយ ។ សិស្សទាំងអស់ដែលស្ថិតក្នុងប្រព័ន្ធអប់រំសាធារណៈរបស់សហគមន៍ Commonwealth ដែលមានរួមទាំង សិស្សពិការក៏ត្រូវបានផ្តល់ជូនសិទ្ធិមានឱកាសសិក្សា មុខវិជ្ជាដែលបានបំពេញតាមបទដ្ឋានសិក្សាក្នុងគោលការណ៍មុខវិជ្ជានៅរដ្ឋ Massachusetts ។ រដ្ឋ Massachusetts ក៏ផ្តល់សិទ្ធិជាលក្ខណៈបុគ្គលដល់ការសិក្សាជាសាធារណៈសមរម្យដោយឥតគិតថ្លៃ FAPE សំរាប់សិស្សពិការ ដែលមានលំនៅដ្ឋានជាក់លាក់ ហើយកំពុងសិក្សានៅឯសាលាឯកជនដោយចំណាយថវិកាខ្លួនឯង ហើយសិស្សដែលកំពុងស្វែងរកសេវាកម្មអប់រំពិសេសសាធារណៈ។

ច្បាប់រដ្ឋ និង សហព័ន្ធ មានវិធាននានាសំរាប់សាលារៀនស្រុកត្រូវអនុវត្ត នៅពេលការធ្វើសេចក្តីសំរេចថាតើ សិស្សត្រូវមាន សិទ្ធិទទួលការអប់រំពិសេសឬអត់ ហើយប្រសិនបើមានសិទ្ធិទទួល សាលាត្រូវសំរេចថាតើសិស្សត្រូវទទួលសេវាកម្មអ្វី ។ ច្បាប់ទាំងនេះមាននីតិវិធីយ៉ាងពិស្តារដើម្បីធានាឲ្យប្រាកដថា សិស្សនឹងត្រូវទទួលកម្មវិធី FAPE ក្នុងកំឡុងពេលដែលពួកគេទទួលការអប់រំពិសេស។ ការអប់រំពិសេស គឺជាវិស័យអប់រំច្បាប់សិក្សាដែលមាន លក្ខណៈស្មុគស្មាញ។ សេចក្តីពិស្តារនៃច្បាប់ មានគោលបំណងសំរាប់ការពារកូនអ្នក និងដើម្បីជួយធានាថាសិស្សត្រូវទទួលសេវាកម្មអប់រំសមរម្យ។ អ្នកអាចទទួលជំនួយបន្ថែមពីការិយាល័យណែនាំនៅសាលាអ្នក ដើម្បីធ្វើឲ្យអ្នកយល់អំពីដំណើរការនៃការអប់រំ ពិសេសរបស់មន្ទីរអប់រំបឋមសិក្សា និង មធ្យមសិក្សា Massachusetts Department of Elementary and Secondary Education (ESE),- អង្គភាពនានាសំរាប់ឲ្យមាតាបិតាសិស្សពិការអនិងអង្គភាពអប់រំជាលក្ខណៈបុគ្គលដ៏ពិសេស ។ ព័ត៌មានបានមកពីប្រភពទាំងនេះនឹងជួយអ្នកឲ្យធ្វើការជាដៃគូរ ជាមួយសាលារៀនថ្នាក់ស្រុក ដើម្បីធ្វើឲ្យប្រាកដប្រជាថា កូនរបស់អ្នកត្រូវមានសិទ្ធិទទួលសេវាកម្មអប់រំ ពិសេសដ៏សមរម្យមួយ។ មន្ទីរអប់រំបឋមសិក្សា និងមធ្យមសិក្សា ESE ផ្សព្វផ្សាយព័ត៌មានទូលំទូលាយសម្រាប់មាតាបិតា និងសាលារៀនស្រុកអំពីគេហទំព័ររបស់ខ្លួន។ តារាងមាតិកានៃគេហទំព័រ ESE នៃមន្ទីរអប់រំបឋមសិក្សា និងមធ្យមសិក្សា (ESE) រួមបញ្ចូលនៅផ្នែកចុងក្រោយនៃលិខិត ជូនដំណឹងនេះ។

សេចក្តីជូនដំណឹងនេះផ្តល់ជូនព័ត៌មានដ៏សំខាន់មួយស្តីពីសិទ្ធិរបស់អ្នកដែលពាក់ព័ន្ធនឹងការធ្វើផែនការផ្នែកអប់រំពិសេសសំរាប់កូនរបស់អ្នក។ ការការពារតាមនីតិវិធីគឺជាវិធានជាក់លាក់មួយដើម្បីធ្វើឲ្យប្រាកដថាអ្នកនឹងដឹងនូវអ្វីដែលសាលារៀនស្រុកកំពុងស្នើសុំដើម្បីអនុវត្ត ("ទទួលសេចក្តីជូនដំណឹង") និងឲ្យយល់ព្រមជាមួយផែនការសាលារៀនស្រុក ("ផ្តល់ជូនការព្រមព្រៀងពីមាតាបិតា) និងព្រមទាំងធ្វើឲ្យមានឱកាសច្រើន សំរាប់ដោះស្រាយភាពមិនចុះសម្រុងជាមួយសាលារៀនថ្នាក់ស្រុក (សវនាការយុត្តិធម៌) ។ ការការពារតាមនីតិវិធីដែលមានចែងក្នុងច្បាប់ផ្តល់ជូនការការពារបន្ថែម ដូចមានចែងក្នុងឯកសារនេះស្រាប់។

យើងខ្ញុំសង្ឃឹម ថាសេចក្តីជូនដំណឹងនេះនឹងជាជំនួយមួយសំរាបអ្នក ពីព្រោះថាអ្នកមានបទពិសោធន៍ដើរតួយ៉ាងសកម្មក្នុងការអប់រំកូនរបស់អ្នក។

ឯកសារនេះ សេចក្តីជូនដំណឹងស្តីពីការការពារតាមនីតិវិធី ឆ្លើយតបទៅនឹងសំណួរខាងក្រោមៈ


1. តើអ្វីទៅហៅថា "សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន" ហើយតើអ្នកអាចទទួលសេចក្តីជូនដំណឹងនេះនៅពេលណា? ទំព័រ 2
2. តើអ្វីទៅហៅថា "ការយល់ព្រមពីមាតាបិតា? ហើយតើនៅពេលណាទើបសាលារៀនស្រុកសួររកការយល់ព្រមរបស់អ្នក? ទំព័រ 3
3. តើសាលារៀនស្រុកតម្រូវឲ្យមានការវាយតំលៃលើសំណើសុំដោយមាតាបិតាឬទេ? ទំព័រ 5
4. តើអ្វីទៅហៅថា "ការវាយតំលៃលើការអប់រំដោយឯករាជ្យ"? ទំព័រ 5


[1] មើលការណែនាំអំពីដំណើរការកម្មវិធី IEP សម្រាប់ព័ត៌មានអំពីថាតើកម្មវិធី IEP របស់សិស្សត្រូវបានអភិវឌ្ឍនិងអនុវត្តយ៉ាងដូចម្តេច។

5. តើអ្នកអាចមើលកំណត់ត្រាសិស្សរបស់អ្នកនៅពេលណាខ្លះ? ទំព័រ 6
6. តើឪពុកម្តាយនិងសាលារៀនអាចដោះស្រាយជម្លោះដោយវិធីណា? ទំព័រ 7
7. តើអ្នកទទួលខុសត្រូវអ្វីខ្លះប្រសិនបើអ្នកឲ្យសិស្សចូលរៀនសាលាឯកជន? ទំព័រ 11
8. តើត្រូវរៀបចំផែនការអ្វីខ្លះសំរាប់បញ្ជូនកូនអ្នកចេញពីសាលារៀន? ទំព័រ 12
9. តើសាលារៀនអាចដាក់វិន័យសិស្សពិការដោយវិធីណា? ទំព័រ 12
10. តើអាចស្វែងរកច្បាប់ បទបញ្ជា និង ព័ត៌មានសំខាន់ៗផ្សេងទៀតនៅកន្លែងណា? ទំព័រ 14

អ្នកនឹងទទួលសេចក្តីជូនដំណឹងនេះមួយឆ្នាំម្តង ប្រសិនបើសិស្សរបស់អ្នក ត្រូវបានគេកំណត់ថាមានសិទ្ធិទទួលការសិក្សាពិសេស។ អ្នកអាចស្នើសុំកំណត់ហេតុថតចម្លងមួយច្បាប់ពីសាលារៀនស្រុក ឬ ពី ESE នៅពេលណាក៏បាន។ ឯកសារ នេះ មាននៅក្នុងគេហទំព័រ ESE: http://www.doe.mass.edu/sped/prb ។

## 1. តើអ្វីទៅហៅថា សេចក្តីជូនដំណឹងលាយលក្ខណ៍អក្សរជាមុន ហើយតើអ្នកអាចទទួលសេចក្តីជូនដំណឹងនេះ នៅពេលណា?

**34 CFR§300 503**

សាលារៀនស្រុកត្រូវផ្តល់សេចក្តីជូនដំណឹងដល់អ្នកជាលាយលក្ខណ៍អក្សរ នៅពេលដែលសាលាស្នើសុំ ឬ បដិសេធ ដើម្បីចាត់វិធានការពិនិត្យមើលសិស្ស វាយតម្លៃ –និងផ្តល់សេវាកម្មពិសេសដល់ សិស្សរបស់អ្នក ឬ ដើម្បីធ្វើការផ្លាស់ប្តូរ កម្មវិធីសិក្សារបស់សិស្ស។ បទបញ្ជាសហព័ន្ធនេះត្រូវបានគេ ហៅថា ″សេចក្តីជូនដំណឹងលាយលក្ខណ៍អក្សរជាមុន ″សេចក្តីជូនដំណឹងនោះត្រូវ:

- ពិពណ៌នាអំពី***អ្វីខ្លះ***ដែលសាលារៀនស្រុកស្នើសុំ ឬ បដិសេធអ?
- ពន្យល់ថា***ហេតុអ្វី*** បានជាសាលារៀនស្រុកស្នើសុំ ឬ បដិសេធមិនចាត់វិធានការ?
- ពិពណ៌នាអំពី***របៀប*** ដែលសាលារៀនស្រុកបានសំរេចស្នើសុំ ឬបដិសេធមិនចាត់វិធានការ ដូចជាប្រាប់អ្នកអំពីនីតិវិធីវាយតម្លៃ ការស្ទាបស្ទង់ កំណត់ត្រា ឬ របាយការណ៍ដែលសាលា ប្រើប្រាស់សំរាប់ធ្វើសេចក្តីសំរេចចិត្ត និង
- ពិព័ត៌នាអំពីជំរើសដែលត្រូវបានពិចារណា និងមូលហេតុដែលត្រូវបានបដិសេធដោយក្រុមកម្មវិធីសិក្សាលក្ខណៈបុគ្គល (IEP) សំរាប់កូនអ្នក។

សាលារៀនស្រុក និងផ្តល់ជូនព័ត៌មាននេះដល់អ្នកដោយប្រើប្រីស់ទំរង់បែបបទ ESE ដែលបានបង្កើតរួចជាស្រេចហើយ ព័ត៌មាននេះមាននៅក្នុងគេហទំព័ររបស់ ESE ឬ ក្នុងទំរងបែបបទនោះក៏មាន ព័ត៌មានដូចគ្នានេះដែរ។

អ្នកត្រូវទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ នៅពេលសាលារៀនធ្វើសកម្មភាពនានាដូចជា: ស្នើសុំវាយ តម្លៃបឋម ឬ វាយតម្លៃសារជាថ្មី ស្នើសុំថ្មី ឬ ស្នើសុំការកែប្រែ IEP ស្នើសុំធ្វើផ្លាស់ប្តូរកន្លែងសិក្សារបស់សិស្សដោយសារមូលហេតុនៃការដាក់វិន័យ ឬ ដោយបញ្ចប់សេវាកម្មអប់រំពិសេសនេះ ។

អ្នកនឹងត្រូវទទួលសេចក្តីជូនដំណឹង ប្រសិនបើសាលារៀនរកឃើញថាកូននាក់ពុំមានសិទ្ធិទទួលការអប់រំពិសេស ឬ សាលារៀនបដិសេធការស្នើសុំឲ្យធ្វើការវាយតម្លៃ ឬស្នើសុំសេវាកម្មអប់រំពិសេសដល់សិស្ស។ សេចក្តីជូនដំណឹងរបស់សាលាត្រូវសរសេរជាភាសាដើមរបស់អ្នក ឬដោយមធ្យោយដែលអ្នកធ្លាប់ប្រើប្រាស់ លើកលែងតែមធ្យោបាយនោះមិនអាចធ្វើបាន។ ប្រសិនបើភាសាកំណើត ឬមធ្យោបាយនោះមិនមែនជាភាសាសរសេរសាលាត្រូវធានាខុសត្រូវថា សេចក្តីជូនដំណឹងនោះ ត្រូវបកប្រែជូនអ្នកដោយផ្ទាល់មាត់ ឬតាមមធ្យោបាយផ្សេងៗទៀត (ភាសាជានិមិត្តសញ្ញា) ធ្វើយ៉ាងណាឲ្យតែអ្នកយល់អំពីអត្ថន័យដែលមានក្នុងសេចក្តីជូនដំណឹងនោះ។

សាលារៀនស្រុកនឹងផ្តល់ជូនអ្នកនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ និងស្នើសុំការព្រមព្រៀងរបស់អ្នក–ឬកាអនុញ្ញាតជាលាយលក្ខណ៍អក្សរផងដែរ – មុនសាលារៀនស្រុកសុំឲ្យប្រើប្រាស់ការធានារ៉ាប់រងសុខភាពសាធារណ: (MassHealth ឬ Medicaid)ដើម្បីបង់ប្រាក់សេវាកម្មអប់រំពិសេសរបស់សិស្សសម្រាប់លើកដំបូង។

នៅពេលដែលគេជូនដំណឹងដល់អ្នកជាលាយលក្ខណ៍អក្សរ គេក៏ផ្តល់ព័ត៌មានស្តីពីការការពារតាមនីតិវិធីមួយច្បាប់ដល់អ្នកផងដែរ ឬ ប្រសិនបើអ្នកបានទទួលសេចក្តីជូនដំណឹងនោះរួចហើយក្នុងកំឡុងឆ្នាំសិក្សាបច្ចុប្បន្ន គេនឹងប្រាប់អ្នកអំពីវិធីដែលអ្នកអាចស្វែងរកការការពារតាមនីតិវិធីមួយច្បាប់ទៀតដោយខ្លួនឯង។ អ្នកនឹងទទួលព័ត៌មានពីមនុស្សដែលអាចជួយពន្យល់អ្នកយល់អំពីច្បាប់អប់រំពិសេសរបស់រដ្ឋ និងសហព័ន្ធ។

## 2. តើអ្វីទៅហៅថាការយល់ព្រមពីមាតាបិតា? **34CFR§300.9 AND 603 CMR 28.07(1)**

សាលារៀនស្រុកប្រហែលជាមិនអាចឲ្យកូនអ្នកធ្វើការប្រឡងសាក ឬ ផ្តល់សេវាកម្មអ្វីពិសេសឡើយ លើកលែងតែអ្នកព្រមព្រៀង ហើយផ្តល់ "ការយល់ព្រមពីមាតាបិតា" ជាលាយលក្ខណ៍អក្សរ។ សាលារៀនស្រុកត្រូវទាក់ទងមកអ្នក ហើយពន្យល់យ៉ាងច្បាស់ អំពីអ្វីដែលសាលារៀនកំពុងតែស្នើសុំដើម្បីអនុវត្តសំរាប់កូនរបស់អ្នក។ ហើយបន្ទាប់មកសាលារៀនស្រុកនឹងសុំឲ្យអ្នកចុះហត្ថលេខា និង ឈ្មោះរបស់អ្នក លើបែបបទព្រមព្រៀង សាលារៀនស្រុកដើម្បីបង្ហាញថាអ្នកយល់ព្រមតាមសំណើរបស់សាលា។ សាលារៀនស្រុកនេះគឺការប្រគល់ "ការព្រមព្រៀងពីមាតាបិតា"។

កាប្រគល់ការព្រមព្រៀងរបស់អ្នក គឺធ្វើដោយស្ម័គ្រចិត្ត ។ អ្នកអាចយកត្រឡប់មកវិញ ឬលុបចោលបែបបទព្រមព្រៀងរបស់អ្នក នៅពេលណាក៏បាន។ ប្រសិនបើអ្នកមានបំណងចង់លុបចោលការព្រមព្រៀងនោះ អ្នកត្រូវអនុវត្តជាលាយលក្ខណ៍អក្សរ។ ប្រសិនបើអ្នកដកយកវិញការព្រមព្រៀងនោះ នឹងអនុវត្តសំរាប់តែសកម្មភាពនាពេលអនាគតប៉ុណ្ណោះតាមរយៈសាលារៀនស្រុក ដែលមិនអនុវត្តចំពោះអ្វីដែលសំរេចរួចហើយនោះទេ ។ សាលារៀនស្រុករបស់អ្នក អាចមិនប្រើការបដិសេធរបស់អ្នកចំពោះការព្រមព្រៀងឲ្យទទួលយកសេវាកម្ម ឬសកម្មភាពមួយ ដោយផ្អែកលើមូលហេតុបដិសេធអ្នក ឬសិស្សរបស់អ្នកចំពោះសេវាកម្ម អត្ថប្រយោជន៍ ឬសកម្មភាពផ្សេងទៀត។

គេ<u>មិន</u>ទាន់តម្រូវឲ្យអ្នកធ្វើការព្រមព្រៀងនៅឡើយទេ លុះត្រាតែសាលារៀនស្រុកបញ្ចប់ ការពិនិត្យលើទិន្ន័យមានស្រាប់ជាផ្នែកមួយនៃការវាយតម្លៃ ឬ បញ្ចប់ ការវាយតម្លៃសិស្សសារ ជាថ្មីម្តងទៀតសិន ។ ការប្រឡងសាក ឬ វាយតម្លៃសិស្ស ត្រូវតែធ្វើចំពោះសិស្សគ្រប់រូបដោយមិនបាច់ការព្រមព្រៀងទេ ដូចជា MCAS ឬ ការប្រឡងសាកក្នុងថ្នាក់ ជាផ្នែកមួយនៃកម្មវិធីអប់រំទូទៅ ឬក៏ចែករំលែកព័ត៌មានជាមួយ មន្ត្រីអប់រំ របស់រដ្ឋ ឬសហព័ន្ធដែរ។

### 2.1 តើសាលារៀនស្រុកស្នើសុំការព្រមព្រៀងពីអ្នកនៅពេលណា? **34 CFR §§ 300.300, 300.154 AND 603 CMR 28.07(1)**

សាលារៀននឹងស្នើសុំការយល់ព្រមពីមាតាបិតាក្នុងកាលៈទេសៈដូចខាងក្រោម

**ដើម្បីផ្តល់សិទ្ធិអនុញ្ញាតឱ្យមានការវាយតម្លៃបឋម ដើម្បីកំណត់ថាតើសិស្សម្នាក់ៗមានសិទ្ធិទទួលការអប់រំពិសេសដែរទេ**
សាលារៀនស្រុកមិនអាចធ្វើការវាយតម្លៃបឋមទៅលើសិស្សរបស់អ្នកដើម្បីកំណត់ថាតើសិស្សរបស់អ្នកមានសិទ្ធិទទួលការអប់រំពិសេស និង/ឬសេវាកម្មផ្សេងៗទៀតដោយមិនមានការទទួលការព្រមព្រៀងពីអ្នកជាមុនឬអត់ឡើយ។ បើសិនមានការវាយតម្លៃកូនរបស់អ្នក សាលារៀនត្រូវតែស្នើសុំការយលព្រមពីអ្នកដើម្បីធ្វើការវាយតម្លៃនោះក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃសិក្សា ។

**ដើម្បីអនុម័តលើសេវាកម្មបឋម**
បន្ទាប់ពីការវាយតម្លៃបឋមចប់សព្វគ្រប់ហើយ ប្រសិនបើក្រុមកម្មវិធីអប់រំលក្ខណៈបុគ្គល (IEP) សំរេចថាកូនរបស់អ្នកមានសិទ្ធិទទួលបាននូវការអប់រំពិសេសនោះ ក្រុម IEP នឹងឯងស្នើសុំការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធនានាសំរាប់កូនអ្នក។ អ្នកជាសមាជិករបស់ក្រុមកម្មវិធី IEP ហើយអ្នកត្រូវតែផ្តល់ការយល់ព្រមរបស់អ្នក មុនពេលសាលារៀនស្រុកអាចផ្តល់ជូនការអប់រំពិសេស និង សេវាកម្មនានាដែលពាក់ព័ន្ធដល់កូនរបស់អ្នកជា <u>លើកទីដំបូង</u> ។ ប្រសិនបើអ្នកមិនយល់ព្រមទេ សាលាស្រុកក៏មិនអាចផ្តល់ជូនការអប់រំពិសេស និង សេវាកម្មនានាដែលពាក់ព័ន្ធដល់កូនរបស់អ្នកឡើយ ។ អ្នកអាចទទួលយក ឬ បដិសេធសំណើទាំងស្រុងក៏បាន ឬក៏ទទួលយក ឬ បដិសេធផ្នែកណាមួយនៃសំណើនោះក៏បានដែរ ។ កម្មវិធី IEP ឬ ផ្នែកណាមួយដែលអ្នកទទួលយក ត្រូវចាប់ផ្តើមភ្លាមៗបន្ទាប់ពីអ្នកបានទទួលវា។

**ដើម្បីធ្វើការផ្លាស់ប្តូរសេវាកម្មនានា កន្លែងសិក្សា ឬ ការវាយតម្លៃឡើងវិញ**
ខណៈពេលដែលអ្នកព្រមទទួលយកកម្មវិធី IEP សំរាប់សិស្សរបស់អ្នកហើយ សាលារៀនស្រុកត្រូវទទួលការព្រមព្រៀងរបស់អ្នក មុនពេលសាលារៀនស្រុកអាចផ្លាស់ប្តូរសេវាកម្មនានា ឬ កន្លែងសិក្សា ឬ ធ្វើការវាយតម្លៃឡើងវិញ[2] ។ ប្រសិនបើអ្នកបដិសេធផ្តល់ជូនការយល់ព្រមរបស់អ្នក អ្នកមានកាតព្វកិច្ចមួយដើម្បីពាក់ព័ន្ធជាមួយសាលារៀនស្រុក ដើម្បីធ្វើការពិភាក្សាយ៉ាងសកម្មដើម្បីដោះស្រាយចំពោះការជំទាស់របស់អ្នក។ ប្រសិនបើអ្នកបានផ្តល់ជូនការយល់ព្រមចំពោះសេវាកម្មនាពេលកន្លងទៅ ហើយឥឡូវចង់លុបចោលការព្រមព្រៀង ហើយដកយកសិស្សរបស់អ្នកពីសេវាកម្មនានានោះ អ្នកត្រូវអនុវត្តដូច្នេះជាលាយលក្ខណ៍អក្សរ។ សាលាស្រុកអាចមិនស្នើសុំឲ្យមានសវនាការនៅការិយាល័យប្តឹងតវ៉ាផ្នែកអប់រំពិសេស Bureau of Special Education Appeals (BSEA) ដើម្បីសុំការអនុញ្ញាតផ្តល់សេវាកម្មអប់រំ ឬធ្វើការវាយតម្លៃកូនរបស់អ្នកជាថ្មី ដោយមិនចាំបាច់មានការព្រមព្រៀងរបស់អ្នក។

[2] អ្នកក៏មានសិទ្ធិតាមដានសិស្សរបស់អ្នកក្នុងកម្មវិធីបច្ចុប្បន្នរបស់គេ និងតាមដានកម្មវិធីដែលបានស្នើសុំមុនការធ្វើតេស្តចូលរបស់សិស្សអ្នក។ សម្រាប់ព័ត៌មានបន្ថែម សូមមើលឯកសារនៃមន្ទីរអប់រំបឋមសិក្សា និងមធ្យមសិក្សា ESE "ការតាមដានកម្មវិធីអប់រំដោយមាតាបិតាសិស្ស"។

**ដើម្បីទទួលបានអត្ថប្រយោជន៍ពីកម្មវិធី (MassHealth ឬ Medicaid) ការធានារ៉ាប់រងសុខភាពសាធារណៈលើកដំបូង**

សាលារៀនស្រុកត្រូវបានអនុញ្ញាតប្រើប្រាស់ការធានារ៉ាប់រងសុខភាពសាធារណៈ (MassHealth ឬ Medicaid) ដើម្បីបង់ប្រាក់ជូនសេវាកម្មអប់រំពិសេសមួយចំនួនដែលបានរាប់បញ្ចូលកម្មវិធី IEP របស់សិស្ស សម្រាប់សិស្សនានាដែលបានចេញថ្លៃការធានារ៉ាប់រងសុខភាពសាធារណៈ។ សាលារៀនស្រុកទទួលបានកម្មវិធី MassHealth លើកដំបូងនោះ សាលារៀនស្រុកត្រូវផ្តល់ជូនអ្នកនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ដែលសាលាកំពុងតែស្វែងរកសំណាងនេះ ហើយទទួលការព្រមព្រៀងស្ម័គ្រចិត្តរបស់អ្នកក្នុងការសរសេរជាលាយលក្ខណ៍អក្សរសម្រាប់សាលា។ សេចក្តីជូនដំណឹងនេះនឹងប្រាប់អ្នកថា ជានិច្ចកាលសេវាកម្មអប់រំពិសេសត្រូវបានផ្តល់ជូនអ្នក ឬក្រុមគ្រួសារអ្នកដោយឥតគិតថ្លៃ; នឹងបញ្ជាក់ច្បាស់ថាការព្រមព្រៀងរបស់អ្នកនឹងមិនបង្កឲ្យមានផ្លាស់ប្តូរផ្សេងៗនៅក្នុងការធានារ៉ាប់រង ឬភាពមានសិទ្ធិស្របច្បាប់ពីកម្មវិធី MassHealth របស់កូនអ្នកឡើយ; នឹងពិពណ៌នាអំពីព័ត៌មានសិស្សអ្នក នឹងត្រូវបានចែករំលែក ដើម្បីទទួលបានកម្មវិធី MassHealth; រំឭកអ្នកថាការព្រមព្រៀងរបស់អ្នក អាចត្រូវបានដកចេញបានគ្រប់ពេលវេលា; ហើយបញ្ជាក់ច្បាស់ថា នឹងពុំមានការផ្លាស់ប្តូរនានាចំពោះសេវាកម្ម ឬកម្មវិធីអប់រំពិសេសរបស់សិស្សអ្នក ប្រសិនបើអ្នកដកចេញ ឬមិនផ្តល់ជូនការព្រមព្រៀង។ ប្រសិនបើអ្នករើផ្ទះសម្បែង ឬសិស្សអ្នកបានចុះឈ្មោះរៀននៅស្រុកផ្សេងទៀត បន្ទាប់មកសាលារៀនស្រុកថ្មី នឹងស្នើសុំអ្នកឲ្យផ្តល់ជូនការព្រមព្រៀងម្តងទៀត។

**ដើម្បីដកភារៈកិច្ចពីសមាជិកក្រុមកម្មវិធី IEP ឲ្យការចូលរួមប្រជុំក្រុម**

សមាជិកក្រុម IEP អាចរួចផុតភារៈកិច្ចដោយមិនបាច់ចូលរួមប្រជុំជាមួយក្រុមការងារទេ ប្រសិនបើអ្នកយល់ព្រមដោយលាយលក្ខណ៍អក្សរមុនពេលប្រជុំចាប់ផ្តើម។ ប្រសិនបើក្រុមការងារធ្វើការពិភាក្សាអំពីសមាជិកដែលមិនមានភារៈកិច្ច សមាជិករូបនោះត្រូវផ្តល់យោបល់របស់ខ្លួនជាលាយលក្ខណ៍អក្សរឲ្យបានមុនការប្រជុំក្រុមការងារចាប់ផ្តើម។ ប្រសិនបើអ្នកមិនយល់ព្រមដកភារៈកិច្ចសមាជិកក្រុមណាម្នាក់ទេ សមាជិកនោះត្រូវតែចូលរួមប្រជុំក្រុម IEP ដែរ។

## 2.2 តើការស្នើសុំការព្រមព្រៀងពីសិស្សនៅពេលណា?

**34CFR§300.520 AND 603 CMR 28.07(5)**

តាមច្បាប់រដ្ឋ Massachusetts កំណត់ថា សិស្សពេញវ័យនៅអាយុ (18 ឆ្នាំ)។ នៅ**ពេលដែលសិស្សមានអាយុ 18 ឆ្នាំ** ឪពុកម្តាយត្រូវផ្តល់សិទ្ធិឲ្យកូនធ្វើសេចក្តីសំរេចចិត្តនៅពេលដែលកូនគ្រប់អាយុពេញវ័យ លើកលែងតែមានសេចក្តីសំរេចពីតុលាការជាលាយលក្ខណ៍អក្សរដែលបានតែងតាំងអាណាព្យាបាលស្របច្បាប់ក្នុងការធ្វើសេចក្តីសំរេចចិត្ត ឬ កូនរបស់អ្នកបញ្ជាក់ជាលាយលក្ខណ៍អក្សរថាគាត់ចង់ចែករំលែកការធ្វើសេចក្តីសំរេចចិត្តជាមួយអ្នក ឬចង់បន្តឲ្យមានសិទ្ធិអនុញ្ញាតដើម្បីធ្វើសេចក្តីសំរេចចិត្តលើកម្មវិធីអប់រំរបស់គាត់។ សាលរៀនស្រុកត្រូវតែពិភាក្សាជាមួយអ្នក និងកូនរបស់អ្នកអំពីផលប៉ះពាល់នៃការផ្ទេរសិទ្ធិនេះ ដែលយ៉ាងហោចណាស់ក្នុងរយៈពេលមួយឆ្នាំ មុនពេលកូនមានអាយុគ្រប់ ដប់ប្រាំបីឆ្នាំ ។ បើអ្នកជាមាតាបិតារបស់កូនពិការដែលមានអាយុពេញវ័យ អ្នកនឹងត្រូវបន្តទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរពីសាលាជា ហើយអ្នកនឹងបន្តពិនិត្យមើលលើកំណត់ហេតុសិក្សាកូនរបស់អ្នកបាន ទោះបីកូននោះធ្វើការសំរេចចិត្តលើការសិក្សាដោយខ្លួនឯងក៏ដោយ។

## 2.3 តើអ្នកតំណាងមាតាបិតាក្នុងការអប់រំផ្តល់ការព្រមព្រៀងនៅពេលណា?

**34CFR§300.519 (g)) 603 CMR 28.07(7)**

ប្រសិនបើកូនស្ថិតនៅក្រោមការឃុំឃាំងរបស់មន្ទីរកិច្ចការសង្គម Department of Children and Families ឬ ឪពុកម្តាយ ឬ អាណាព្យាបាលរបស់សិស្សមិនអាចត្រូវបានកំណត់អត្តសញ្ញាណ ឬទីកន្លែង ឬមានសិទ្ធិអំណាចមេបាដែលបានបញ្ចប់នោះ ESS មានការទទួលខុសដើម្បីធានាថាមានមនុស្សពេញវ័យមួយនាក់ដែលមិនមានទំនាស់ផលប្រយោជន៍ដើម្បីឲ្យធ្វើសេចក្តីសំរេចចិត្តលើការអប់រំពិសេសជំនួសសិស្ស។ អ្នកធ្វើសេចក្តីសំរេចចិត្តនោះហៅថា តំណាងមាតាបិតាការអប់រំពិសេស។ ESS ត្រូវកំណត់ ថាតើចាំបាច់ត្រូវជ្រើសតាំងតំណាងមាតាបិតាឲ្យការអប់រំពិសេសសម្រាប់សិស្សឬអត់។ ប្រសិនបើចាំបាច់ បានតែងតាំងនោះ តំណាងមាតាបិតាការអប់រំពិសេសមានសិទ្ធិ និងការទទួលខុសត្រូវដូចគ្នាជាមាតាឬបិតាក្នុងបញ្ហាសិក្សាពិសេសសម្រាប់សិស្ស។

## 2.4 តើខ្ញុំត្រូវដកយកការព្រមព្រៀងដោយរបៀបណា?

**34 CFR §300.300(B)(4) and 300.9**

ប្រសិនបើអ្នកបានផ្តល់ការព្រមព្រៀងចំពោះការទទួលសេវាកម្មសិក្សាពិសេស និងសេវាកម្មពាក់ព័ន្ធ ហើយឥឡូវនេះអ្នកចង់លុបចោលការព្រមព្រៀងរបស់អ្នក អ្នកត្រូវអនុវត្តជាលាយលក្ខណ៍អក្សរ។ អ្នកអាចដកយកការព្រមព្រៀងរបស់អ្នកចំពោះគ្រប់ការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធទាំងអស់ ចំពោះសេវាកម្មជាក់លាក់ ឬចំពោះការធ្វើតេស្តចូលរៀន ឬចំពោះការប្រើប្រាស់កម្មវិធី MassHealth នៅស្រុក ឬការធានារ៉ាប់រងកម្មវិធី Medicaid សម្រាប់សិស្សអ្នក។ នៅពេល ដែល

សាលារៀនស្រុកបានទទួលលិខិតរបស់អ្នក សាលារៀនស្រុកនឹងផ្ញើលិខិតជូនដំណឹងអំពីការចាប់ផ្តើមផ្លាស់ប្តូរ ប្រសិនបើមាន ក្នុងការធ្វើតេស្ត ចូលរៀន និងសេវាកម្មនានាដែលទទួលលទ្ធផលពីការលុបចោលការព្រមព្រៀងរបស់អ្នក។ នៅពេលដែលអ្នកដកយកការព្រមព្រៀងរបស់អ្នកចំពោះការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធទាំងអស់សាលារៀនស្រុកនឹងមិនតម្រូវឲ្យសិស្សរបស់អ្នកធ្វើការអប់រំសាធារណៈដោយឥតគិតថ្លៃ និងសមរម្យតាមសមត្ថភាព FAPE តទៅទៀតឡើយ ឬមានការប្រជុំកម្មវិធី IEP ឬអភិវឌ្ឍកម្មវិធី IEP សម្រាប់សិស្សរបស់អ្នក។ សាលារៀនស្រុកមិនតម្រូវឲ្យធ្វើការផ្លាស់ប្តូរកែតម្រូវកំណត់ត្រាសិស្សរបស់អ្នកដើម្បីដកយកឯកសារទាក់ទងនឹងសេវាអប់រំពិសេសជាលិទ្ធផលនៃការលុបចោលការព្រមព្រៀងរបស់អ្នក។

## 3. តើសាលារៀនស្រុកត្រូវបានគេតម្រូវឲ្យវាយតំលៃសិស្សអំពីសំណើពីមាតាឬបិតាឬទេ? 34 CFR §300.301 and 603 CMR 28.04

សិស្សម្នាក់ត្រូវទទួលការវាយតំលៃពេញលេញ និងទូលំទូលាយដើម្បីកំណត់ថាតើ សិស្សមានភាពពិការ ហើយមានសិទ្ធិស្របច្បាប់ចំពោះការអប់រំពិសេស ហើយបើមានសិទ្ធិស្របច្បាប់ ដើម្បីជួយការកំណត់ការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធសមរម្យ ដែលអាចចាំបាច់។ មាតាបិតាដែលមានក្តីបារម្ភអំពីការវិវត្តន៍កូនពួកគេ ឬមានការសង្ស័យអំពីភាពពិការដែលអាចកើតមាន អាចសម្តៅចំពោះកូនពួកគេសម្រាប់ការវាយតំលៃដំបូង។ ពាក្យពិសេសៗដែលត្រូវការដើម្បីប្រើប្រាស់ក្នុងការរៀបចំការបញ្ជូនអ្នកជំនាញសម្រាប់ការវាយតំលៃដំបូង។ នៅពេលទទួលសំណើការវាយតំលៃដំបូង សាលារៀនស្រុកត្រូវផ្ញើជូនសេចក្តីជូនដំណឹងចំពោះមាតាឬបិតា ហើយត្រូវស្វែងរកការព្រមព្រៀងពីមាតាឬបិតា ដើម្បីអនុវត្តការវាយតំលៃនេះ។ (សាលារៀនស្រុក នឹងមានឱកាសដោយកម្រដើម្បីបដិសេធការអនុវត្តការវាយតំលៃដំបូង ហើយអាចអនុវត្តដូច្នោះ បើមាតាឬបិតា ឬបុគ្គលផ្សេងទៀតដែលរៀបចំការបញ្ជូនអ្នកជំនាញ ពុំមានសង្ស័យអំពីភាពពិការ ឬពុំមានក្តីបារម្ភអំពីការវិវត្តន៍របស់សិស្ស)។

នៅទីកន្លែងសមរម្យនោះ សាលារៀនស្រុកក៏អាចផ្តល់ជូនការព្រមព្រៀងជាមួយព័ត៍មានដែលពាក់ព័ន្ធសេវាកម្មគាំទ្រផងដែរ ដែលអាចសមរម្យប្រសើរជាងចំពោះតម្រូវការសិស្សជាក់ស្តែង។ ប៉ុន្តែទោជាយ៉ាងណាក៏ដោយ ក៏សាលារៀនស្រុកអាចមិនបដិសេធវាយតំលៃសិស្សដែលត្រូវបានគេបញ្ជូនអ្នកជំនាញសម្រាប់ការវាយតំលៃ ដូចដែលបានរៀបរាប់ខាងលើផងដែរ ដោយផ្អែកលើកម្មវិធីបញ្ជូនអ្នកជំនាញជាមុន ឬដើម្បីព្យាយាមសកម្មភាពគាំទ្រដែលបានណែនាំផ្សេងៗទៀត ឬសម្រាប់មូលហេតុផ្សេងៗទៀត។ លើសពីនេះ ច្បាប់នេះផ្តល់ជូនការវាយតំលៃឡើងវិញតាមពេលវេលាដើម្បីធានាថាសិស្សទទួលអត្ថប្រយោជន៍ ហើយបន្តស្នើសុំការអប់រំពិសេស។ ជានិច្ចកាលការព្រមព្រៀងពីមាតាឬបិតា នឹងមិនតម្រូវឲ្យមានមុនការវាយតំលៃឡើងវិញឡើយ។

## 4. តើអ្វីទៅហៅថាការវាយតម្លៃលើការអប់រំដោយឯករាជ្យ 34CFR§300.502 AND 603 CMR 28.04(5)

ការវាយតម្លៃលើការអប់រំដោយឯករាជ្យ (IEE) គឺជាការវាយតម្លៃធ្វើឡើងដោយអ្នកត្រួតពិនិត្យដែលមានសមត្ថភាពខ្ពស់ហើយមិនបំរើការក្នុងសាលារៀនស្រុកនេះទេ អ្នកវាយតម្លៃមានភារៈទទួលការងារខាងផ្នែកអប់រំសិស្ស។

អ្នកមានសិទ្ធិស្នើសុំកម្មវិធី IEE សំរាប់កូនរបស់អ្នកដោយចំណាយថវិកាសាធារណៈ ប្រសិនបើអ្នកមិនយល់ស្របជាមួយការវាយតម្លៃរៀបចំដោយសាលារៀនស្រុក។ ប្រសិនបើអ្នកស្នើសុំ IEE សាលារៀនស្រុកត្រូវផ្តល់ព័ត៌មានជូនអ្នកអំពីកន្លែងដែលអ្នកទទួលសេវាកម្មវាយតម្លៃ IEE និងអំពីតម្រូវការទាមទារពីរដ្ឋ ដែលដើម្បីអនុវត្តការវាយតម្លៃ IEEs ។

### 4.1 តើការវាយតម្លៃការអប់រំឯករាជ្យត្រូវចំណាយថវិកាសាធារណៈធ្វើនៅពេលណា?

នៅក្នុង Massachusetts, តាមច្បាប់ អ្នកនឹងទទួលការវាយតម្លៃដោយឯករាជ្យ IEE យ៉ាងពេញលេញការចំណាយថវិកាសាធារណៈ ដែលបានចែករំលែក បើអ្នកបំពេញតម្រូវការទាមទារភាពមានសិទ្ធិស្របច្បាប់ស្តីពីប្រាក់ចំណូល ចំពោះសិស្សដែលទទួលអាហារដោយឥតគិតថ្លៃ ឬ ដោយបង់ថ្លៃបន្តិចបន្តួច មានសិទ្ធិទទួលការវាយតម្លៃ IEE ដោយចំណាយលើថវិកាសាធារណៈ។ សិស្សផ្សេងទៀតដែលមានសិទ្ធិទទួលការវាយតម្លៃ IEE ដោយចំណាយថវិកាដែលបានចែករំលែកតាមតម្លៃមានកំណត់ក្នុងតារាង ។ ការចែករំលែកព័ត៌មានហិរញ្ញវត្ថុផ្ទាល់ខ្លួនជាមួយសាលារៀនស្រុក ត្រូវធ្វើឡើយដោយស្មគ្រ័ចិត្ត។ ប្រសិនបើជ្រើសរើសចែករំលែកព័ត៌មានហិរញ្ញវត្ថុនោះ សាលារៀនស្រុកត្រូវជូនដំណឹងលាយលក្ខណ៍អក្សរ ទៅអ្នកវិញជាបន្ទាន់ ដោយបញ្ជាក់ថាតើអ្នកមានសិទ្ធិស្របច្បាប់ចំពោះការផ្តល់មូលនិធីពេញលេញ ឬភាគខ្លះសម្រាប់ការវាយតម្លៃ IEE នោះត្រូវចំណាយថវិការសាធារណៈទាំងអស់ ឬ ត្រូវចំណាយមួយចំណែក ហើយការបង់ថ្លៃលើការវាយតម្លៃ IEE ត្រូវធ្វើតាមចំណែកនោះ ។ អ្នកមានសិទ្ធិទទួលការវាយតម្លៃដោយចំណាយថវិកាសាធារណៈ IEE តាមការកំណត់ប្រាក់ចំណូលរបស់អ្នកក្នុងកំឡុងពេល 16 ខែ គិតចាប់ ពីថ្ងៃដែល សាលារៀនបានរៀប ចំការវាយតម្លៃ ដែលអ្នកមិនយល់ព្រម។

ប្រសិនបើអ្នកមិនបំពេញតម្រូវការទាមទារភាពមានសិទ្ធិស្របច្បាប់ស្តីពីប្រាក់ចំណូល ឬសំរេចមិនផ្តល់ព័ត៌មានហិរញ្ញវត្ថុទេ សាលារៀននឹងពិចារណាទៅលើសំណើសុំឲ្យមានការវាយតម្លៃដោយចំណាយថវិការសាធារណៈ IEE តាមច្បាប់សហព័ន្ធ ។ ក្នុងរយៈពេល 5 ថ្ងៃ សាលារៀនស្រុក នឹងយល់ព្រមការវាយតម្លៃដោយចំណាយថវិកាសាធារណៈ IEE ឬ ត្រូវស្នើសុំសវនាការដែលនឹងប្រព្រឹត្តនៅឯការិយាល័យតវ៉ាខាងផ្នែកអប់រំពិសេស (Bureau of Special Education Appeals –BSEA) ដើម្បីបញ្ជាក់ថាការវាយតម្លៃនោះពិតជាសមរម្យនិងត្រឹមត្រូវ ។ ព័ត៌មានបន្ថែមស្តីអំពីការវាយតម្លៃ IEEs មាននៅក្នុង ESE Administrative Advisories 2004-1 និង 2001-3 ដែលមាននៅតាមបណ្តាសាលារៀនស្រុកនៅមូលដ្ឋាន និងនៅតាមគេហទំព័រ ESE គឺ៖ http//www.doe.mass.edu/advisories/?sectiion=admin។

អ្នកមានសិទ្ធិចំពោះការវាយតម្លៃ IEE អំពីកូនរបស់អ្នកដោយចំណាយថវិកាសាធារណៈតែមួយដងគត់នៅពេលដែលសាលារៀនស្រុករបស់អ្នក អនុវត្តការវាយតម្លៃម្តងៗ។ អ្នកក៏អាចឲ្យមានការវាយតម្លៃលើកូនរបស់អ្នកដោយឯករាជ្យ ដែលអនុវត្តតាមការចំណាយថវិកាផ្ទាល់ខ្លួនបានបានគ្រប់ពេលវេលាផងដែរ ។

### 4.2 សាលារៀនស្រុកត្រូវពិចារណាលទ្ធផលនៃការវាយតម្លៃ IEEs ក្នុងរយៈពេល 10 ថ្ងៃ

ប្រសិនបើអ្នកទទួលបានការវាយតម្លៃ IEE អំពីកូនរបស់អ្នកដោយចំណាយថវិកាសារធារណៈ ឬក៏ចំណាយថវិកាផ្ទាល់ខ្លួនមួយចំណែកខ្លះជាមួយសាលារៀនស្រុកនោះ ការវាយតម្លៃកូនរបស់អ្នក ដែលអ្នកបានទទួលតាមការចំណាយជាលក្ខណៈឯកជននោះ សាលារៀនស្រុករបស់អ្នកត្រូវរៀបចំការប្រជុំក្រុមមួយក្នុងរយៈពេលដប់ 10 ថ្ងៃ គិតតែថ្ងៃធ្វើការ បន្ទាប់ពីអ្នកទទួលព័ត៌មាននៃការវាយតម្លៃនោះ ។ ក្រុមការងារ នឹងពិចារណាទៅលើលទ្ធផលនៃការវាយតម្លៃ ហើយកំណត់អំពីអ្វីៗ បើមាននោះ ការផ្លាស់ប្តូរត្រូវបានធ្វើឡើងតាមកម្មវិធីសិក្សាលក្ខណៈឯកជនរបស់កូនអ្នក ។

## 5. តើអ្នកអាចមើលកំណត់ត្រាសិស្សរបស់អ្នកនៅពេលណាខ្លះ?

**34 CFR 300.611 AND 603 CMR 23.00**

ក្នុងកំណត់ត្រារបស់សិស្សមានព័ត៌មានដូចជា មុខវិជ្ជាសិក្សា កំណត់ហេតុសាលាបណ្តោះអាសន្ន ហើយរួមមានសុខភាព ការធ្វើតេស្ត ការវាយតម្លៃ វិន័យ និង កំណត់ហេតុផ្សេងទៀត ដែលទាក់ទងទៅនឹងភាពមានសិទ្ធិទទួលបានការអប់រំពិសេស ឬ កម្មវិធីអ្វីមួយ [3] ។ ព័ត៌មានផ្ទាល់ខ្លួនដែលអាចកំណត់បានរបស់សិស្សអ្នកជាការសម្ងាត់ និងប្រហែលជាមិនអាចបង្ហាញដល់នរណាម្នាក់ផ្សេងទៀតក្រៅពីគ្រូបង្រៀន និងមន្ត្រីអប់រំដោយគ្មានការ ព្រមព្រៀងពីអ្នកឡើយ។

អ្នក និងកូនរបស់អ្នក (ប្រសិនបើមានអាយុ 14 ឆ្នាំ ឬ អាយុច្រើនជាងនេះ) មានសិទ្ធិមើលកំណត់ត្រាសិស្ស ខ្លះៗ ឬ មើលបានទាំងអស់ក្នុងរយៈពេល 10 ថ្ងៃ បន្ទាប់ពីថ្ងៃដែលស្នើសុំ ឬ មុនពេលកិច្ចប្រជុំកម្មវិធីសិក្សា IEP ណាមួយ ឬសវនាការយុត្តិធម៌[4]។ អ្នកអាចទទួលព័ត៌មាន កំណត់ហេតុសិស្សច្បតចម្លងមួយច្បាប់អំពីព័ត៌មាននៅពេលស្នើសុំការគិតថ្លៃសមហេតុផលដែលបានកំណត់ចំពោះតម្លៃនៃការផលិតឡើងវិញ។ អ្នកប្រហែលជាមិនត្រូវបង់ថ្លៃសេវាពាក់ព័ន្ធនឹងការស្វែងរក និងទទួលយកកំណត់ត្រាសិស្សរបស់អ្នកទេ។

លើសពីនេះទៅទៀត អ្នកអាចជួបជាមួយបុគ្គលិកសាលាដែលមានលក្ខណៈសម្បត្តិវិជ្ជាជីវៈគ្រប់គ្រាន់ ដើម្បីជួយពន្យល់កំណត់ហេតុសិស្ស។ អ្នកអាចសុំឲ្យអ្នកតំណាងរបស់អ្នក ដូចជា (អ្នកតស៊ូមតិ ទីប្រឹក្សា ឬ មេធាវី ) ត្រួតពិនិត្យសើរើមើល និងបកស្រាយកំណត់ហេតុសិស្ស ប្រសិនបើអ្នកយល់ព្រមជាលាយលក្ខណ៍អក្សរ។ រាល់សិទ្ធិដែលទាក់ទងទៅនឹងកំណត់ហេតុ សិស្សមានចែងនៅក្នុងបទបញ្ជាកំណត់ហេតុសិស្ស Massachusetts Student Record Regulations 603 C.M.R 23.00 ។ បទបញ្ជាទាំងនោះក៏មាន នៅក្នុងគេហទំព័រ: [http//.doe.mass.edu/lawsregs /603cmr23.html](http//.doe.mass.edu/lawsregs/603cmr23.html) ឬតាមការស្នើសុំឯកសារថតចម្លងបទបញ្ជានានាពីសាលារៀនស្រុក ឬ ពី ES។

ជាទូទៅមានតែឪពុកឬម្តាយ សិស្សដែលមានសិទ្ធិស្របច្បាប់ បុគ្គលិកសាលាដែលបានទទួលសិទ្ធិអនុញ្ញាត និងមន្ត្រីអប់រំរបស់រដ្ឋនិងសហព័ន្ធព័ន្ធ ត្រូវបានអនុញ្ញាតឲ្យមើលកំណត់ហេតុសិស្សដោយមិនចាំបាច់មានការយល់ព្រមជាលាយលក្ខណ៍អក្សរ ពីឪពុកម្តាយ ឬ កូនពេញវ័យដែលបានជូនដំណឹងជាក់លាក់។ សាលារៀនស្រុក អាចតម្រូវឲ្យផ្តល់ព័ត៌មានខ្លះជូនមន្ត្រីរដ្ឋ ឬ សហព័ន្ធតាមលទ្ធផលពីការបង្គាប់បញ្ជាពីតុលាការ ឬតាមការឆ្លើយតបទៅនឹងបញ្ហាសុខភាព និងសុវត្ថិភាព ឬ បញ្ហាការអនុវត្តច្បាប់។ ព័ត៌មានដែលមានប្រយោជន៍អំពីបញ្ហាកំណត់ហេតុសិស្សមាននៅក្នុងគេហទំព័រ:
[http//www.doe.mass.edu/lawsregs/advisory/cmr23ganda.htm.](http//www.doe.mass.edu/lawsregs/advisory/cmr23ganda.htm)

## 6. តើឪពុកម្តាយនិងសាលារៀនត្រូវដោះស្រាយជម្លោះដោយវិធីណា?

**34 CFR 300.151,300.506-00.518 AND 603 CMR 28.08**

ច្បាប់របស់រដ្ឋ និងសហព័ន្ធត្រូវផ្តល់ឱកាសដល់ឪពុកម្តាយដើម្បីឲ្យចូលរួមនៅក្នុងការរៀបចំផែនការអប់រំសំរាប់សិស្សពិការ។ ប្រសិនបើឪពុកម្តាយ និងសាលារៀនស្រុកមិនយល់ព្រមអំពីការផ្លាស់ប្តូរដែលទាក់ទងទៅ និងសិទ្ធិទទួលសេវាកម្ម ការវាយតម្លៃឬការផ្លាស់ប្តូរកន្លែងសិក្សារបស់សិស្សពិការ ឬ សេវាកម្ម FAPE ដែលត្រូវគេផ្តល់ដល់សិស្សពិការច្បាប់បើកផ្លូវឲ្យធ្វើការដោះស្រាយចំពោះបញ្ហាមិនចុះសម្រុងនឹងគ្នាដោយមធ្យោបាយច្រើនយ៉ាង។ កូនរបស់អ្នកត្រូវស្ថិតនៅក្នុងកម្មវិធីសិក្សា ឬ កន្លែងសិក្សា

---

[3] ប្រសិនបើមាតាបិតាសិស្សលុបចោលការព្រមព្រៀងរបស់ពួកគេពីសេវាអប់រំពិសេសបន្ទាប់ពីសេវាប្រភេទនេះត្រូវបានចាប់ផ្តើមផ្តល់សាលារៀនស្រុកមិនតម្រូវឲ្យកែប្រែកំណត់ត្រារបស់សិស្សដើម្បីដកឯកសារយោងនៃសេវាអប់រំពិសេសទេ។

[4] សាលារៀនស្រុកកំណត់អំពីការពិនិត្យមើលកំណត់ហេតុរបស់សិស្សប្រសិនបើសាលាបានទទួលលិខិតផ្លូវច្បាប់នានាដូចជាដីកាការពារ ការលែងលះ ឬ ឃុំឃាំងដែលហាមមិនឲ្យបុគ្គលពាក់ព័ន្ធមើលព័ត៌មានរបស់សិស្ស។

បច្ចុប្បន្នសិន ក្នុងកំឡុងពេលមានជម្លោះកើតឡើងទាក់ទងទៅនឹងកន្លែងឲ្យចូលសិក្សា ឬ សេវាកម្មផ្សេងៗ លើកលែងតែអ្នក និង សាលារៀនស្រុកយល់ព្រម ឬផ្លាស់ប្តូរកន្លែងចូលរៀនធ្វើឡើងដោយសារតែការដាក់ពិន័យ។

ខាងក្រោមនេះជាជំរើសសំរាប់អ្នក និង សាលារៀនអាចដោះស្រាយជម្លោះបាន។

### 6.1 ចំណាប់អារម្មណ៍របស់មន្ត្រីសាលាសាធារណៈមូលដ្ឋានអំពីការដោះស្រាយជម្លោះ

ដំណាក់កាលដំបូងដើម្បីធ្វើការដោះស្រាយជម្លោះរបស់អ្នក អ្នកអាចទាក់ទងនាយកសាលា ប្រធានរដ្ឋបាលរបស់កម្មវិធីសិក្សាពិសេស ឬបុគ្គលិកថ្នាក់លើដើម្បីសុំឲ្យជួយអ្នក។ វាជាការល្អប្រសិនបើអ្នកសរសេរជាលាយលក្ខណ៍អក្សរពន្យល់ពីមូលហេតុណាមួយដែលអ្នកព្រួយបារម្មណ៍។

### 6.2 ការប្រើប្រាស់ប្រព័ន្ធដោះស្រាយជម្លោះរបស់ ESE

បើអ្នកគិតថាអ្នកត្រូវការជំនួយពីខាងក្រៅសាលារៀនស្រុក អ្នកអាចទាក់ទង ESE ការិយាល័យកម្មវិធីសេវាកម្មធានាគុណភាព (PQA) តាមទូរសព្ទ័លេខ៖ 781-338-3700 ដើម្បីប្រើប្រាស់ ប្រព័ន្ធដោះស្រាយជម្លោះរបស់រដ្ឋដែលមាននៅក្នុងគេហទំព័រ http://www.doe.mass.edu/edu/pqa/prs/ អ្នកអាចដាក់ពាក្យបណ្តឹងទៅ PQA ប្រឆាំងនឹងការរំលោភច្បាប់ របស់រដ្ឋនិងសហព័ន្ធ ឬ ដើម្បីទទួលជំនួយពី បុគ្គលិករបស់ PQA ឲ្យជួយដោះស្រាយបញ្ហាក្រៅផ្លូវការ ។ ប្រសិនបើ អ្នកចង់បាន ការស៊ើបអង្កេតជាផ្លូវការពី PQA អ្នកត្រូវដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ។ បុគ្គលិករបស់ PQA និង ជួយរៀបចំដាក់ពាក្យបណ្តឹង ។ បណ្តឹងលាយលក្ខណ៍អក្សររបស់អ្នកត្រូវមានរួមដូចជា៖ សរសេរបញ្ជាក់អំពីការ ព្រួយបារម្មណ៍ គោលបំណងនៃដំណោះស្រាយការព្រួយបារម្មណ៍របស់អ្នកដោះស្រាយសកម្មភាពរបស់សាលា ដែលអ្នកមានជំនឿថាអាចដោះស្រាយការព្រួយបារម្មណ៍របស់អ្នក លើសពីនេះទៀតពាក្យបណ្តឹងត្រូវមានហត្ថលេខា និងព័ត៌មានសំរាប់ទំនាក់ទំនង។ ប្រសិនបើពាក្យបណ្តឹងអំពីបញ្ហាទាក់ទងទៅសិស្សណាម្នាក់ អ្នកត្រូវប្រាប់ឈ្មោះរបស់សិស្ស និងអាសយដ្ឋាន និងឈ្មោះសាលារៀន។ បញ្ហាដែលអ្នកត្រូវប្តឹង មិនត្រូវមានរយៈពេលឲ្យលើសពី១ឆ្នាំ គិតចាប់រហូតដល់ថ្ងៃ PQA ទទួលពាក្យបណ្តឹងនោះ។ ប្រសិនបើអ្នកសំរេចប្តឹងតាមប្រព័ន្ធដោះស្រាយជម្លោះជាផ្លូវការរបស់ PQA អ្នកត្រូវផ្ញើពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរមួយច្បាប់ជូនទៅសាលារៀនស្រុកដែលជាកម្មវត្ថុនៃបណ្តឹង ។ PQA និងធ្វើការដោះស្រាយបណ្តឹងរបស់អ្នកក្នុងរយៈពេល 60 ថ្ងៃ ហើយ PQA និងផ្ញើលទ្ធផលព្រមទាំង សេចក្តីសំរេចជូនអ្នកមួយច្បាប់។

ទោះបីជាដាក់ពាក្យបណ្តឹងទៅ PQA អ្នកនៅតែអាចប្រើប្រាស់មធ្យោបាយផ្សេងទៀតដើម្បីដោះស្រាយជម្លោះ ដូចជាការពិភាក្សាជាមួយសាលារៀនស្រុកមូលដ្ឋាន ការសម្របសម្រួលរបស់អ្នក ឬ សវនាការដោយយុត្តិធម៌នៅការិយាល័យបណ្តឹងតវ៉ាផ្នែកអប់រំពិសេស (មានសេចក្តីពិស្តារខាងក្រោម) ដើម្បីដោះស្រាយពាក្យបណ្តឹង[5] របស់អ្នក ។ ប្រសិនបើអ្នកជ្រើសរើសយកសវនាការដោយយុត្តិធម៌ ពាក្យបណ្តឹងដាក់តាមរយៈប្រព័ន្ធដោះស្រាយជម្លោះ និងត្រូវផ្អាកមួយរយៈរហូតដល់ពេលសវនាការយុត្តិធម៌ត្រូវបានដោះស្រាយចប់ជាមុនសិន ។

### 6.3 ស្នើសុំតែងតាំងអ្នកសម្របសម្រួលអព្យាក្រិត្យត្យ

ការសម្របសម្រួល[6] គឺ ជាសេវាកម្មមួយបំពេញការងារដោយអ្នកសម្របសម្រួលឯករាជ្យមានជំនាញ ច្បាប់អប់រំពិសេស និងជាអ្នកមានជំនាញចរចារ ។ ការសម្របសម្រួលអាចប្រព្រឹត្តិទៅក្នុងខណៈ ពេលដែល ឪពុកម្តាយ និង សាលារៀននានា មិនចុះសម្រុងនឹងគ្នាអំពីបញ្ហាអប់រំពិសេស ទោះបីជាពាក្យបណ្តឹងនោះបានដាក់តាមរយៈប្រព័ន្ធដោះស្រាយជម្លោះរបស់ PQA រួចហើយក៏ដោយ ។ អ្នកសម្រប សម្រួល ជួយភាគីខាងឪពុកម្តាយ និង សាលាឲ្យមានការពិភាក្សាអំពីការមិនចុះសម្រុង និងជួយឲ្យផ្តោះទៅរកដំណោះស្រាយដែលភាគីទាំងពីរព្រមព្រៀងទទួលយក។ ការជជែកដេញដោលនៅពេលសម្របសម្រួល

[5] សំរាប់ធ្វើការប្រៀបធៀបមធ្យោបាយដោះស្រាយតាមប្រព័ន្ធដោះស្រាយជម្លោះ ទៅនឹងការដោះស្រាយពាក្យបណ្តឹងតាមដំណើរការយុត្តិធម៌ សូមមើលតាម: http://www.doe.mass.edu/sped/docs.html

[6] ការពិពត៌នាអំពីដំណើរការសម្របសម្រួលមាននៅក្នុងគេហទំព័រ: http//www.doe.mass.edu/bsea/mediation.html

នោះនឹងត្រូវរក្សាជាការសំងាត់ ហើយភាគីទាំងពីរមិនយកការជជែកគ្នានេះ ទៅប្រើប្រាស់នៅថ្ងៃក្រោយទៀតបានទេ ទោះបីជម្លោះនោះក្លាយជាប្រធានបទដែលត្រូវដោះស្រាយតាមសវនាកាផ្លូវការ ឬ តាមនីតិវិធីតុលាការក៏ដោយ។ នៅពេលដែលមានការព្រមព្រៀងគ្នាសេចក្តីសំរេច នោះត្រូវធ្វើលាយលក្ខណ៍អក្សរដែលមានចុះហត្ថលេខាពីភាគីទាំងពីរ និង ត្រូវអនុវត្តដោយតុលាការ។

ការសម្របសម្រួល ត្រូវបានគេកំណត់តាមរយៈការទំនាក់ទំនង BSEA តាមលេខ៖ 617-626-7291។ អ្នកសម្របសម្រួលនិងកំណត់កាល បរិច្ឆេទប្រជុំជាមួយអ្នក និងសាលារៀនស្រុកក្នុងរយៈពេល 30 ថ្ងៃ បន្ទាប់ពីទទួលពាក្យបណ្តឹងសម្របសម្រួល ។ ការសម្របសម្រួលប្រព្រឹត្តិទៅតាមពេលវេលានិងទីកន្លែងដ៏សមរម្យ។ ការចូលរួមត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត ។ ដូច្នេះភាគីឪពុកម្តាយ និងសាលារៀនត្រូវយល់ព្រមចូលរួមក្នុងការសម្របសម្រួលនេះ។ មិនត្រូវចាំបាច់បង់ថ្លៃសេវាកម្មនេះទេ។ ព័ត៌មានបន្ថែមអំពីការសម្របសម្រួល អាចទំនាក់ទំនងទៅ BSEA តាមលេខ៖ 617-626-7250 ហើយអាចរកបានៅក្នុងការបោះពុម្ពផ្សាយតាមរយៈ "សំណួរដែលសាកសួរជាញឹកញាប់អំពីការសម្របសម្រួល[7]" និង "ការពន្យល់អំពីការសម្របសម្រួល[8]" ។

## 6.4 ការស្នើសុំសវនាការយុត្តិធម៌ និងចូលរួមក្នុងការប្រជុំដោះស្រាយជម្លោះ

ប្រសិនបើ អ្នក និង សាលារៀនស្រុក មិនអាចធ្វើការដោះស្រាយភាពមិនចុះសម្រុងនឹងគ្នាបានទេ អ្នកមានសិទ្ធិស្នើសុំឲ្យមន្ត្រីសវនាការអព្យាក្រឹត្យ ស្តាប់បញ្ហានៃភាគីជម្លោះទាំងពីរ ការសួរដេញដោលពិនិត្យមើលភស្តុតាង និងធ្វើសេចក្តីសំរេច ។ សវនាការនេះត្រូវរៀបចំដោយ BSEA ហើយមានឈ្មោះថា សវនាការយុត្តិធម៌។ មន្ត្រីសវនាការរបស់ BSEA តែងតែទទួលការហ្វឹកហ្វឺនច្បាប់អប់រំពិសេស ហើយមិនមានទំនាក់ទំនងផ្ទាល់ខ្លួន ឬ វិជ្ជាជីវៈ ជាមួយភាគីណាមួយដែលពាក់ព័ន្ធនឹងភាពមិនចុះសម្រុងគ្នានេះទេ។

សវនាការយុត្តិធម៌នេះនឹងពិចារណាជម្លោះអំពីភាពមានសិទ្ធិទទួលបានការវាយតម្លៃ IEPs និងកន្លែងចូលសិក្សា ដែលមានរួមទាំងលទ្ធផលនៃដាក់ពិន័យ FAPE និង ការផ្តល់កម្មវិធីអប់រំពិសេស ព្រមទាំងការការពារតាមនីតិវិធីដែលមានចែងក្នុងច្បាប់សហព័ន្ធ និងច្បាប់រដ្ឋសំរាប់ការពារសិស្សពិការ។ អ្នកត្រូវដាក់ពាក្យស្នើសុំសវនាការក្នុងរយៈពេលពីរបន្ទាប់ពីអ្នកបានដឹងហេតុការណ៍ ឬ ចាប់ពីពេលដែលអ្នកគួរតែដឹង[9] អំពី ព្រឹត្តិការណ៍ដែលបណ្តាលឲ្យមានជម្លោះនេះ។ រយៈពេលនេះអាចពន្យាបានយូរបន្តិច ប្រសិនបើអ្នកអាចបង្ហាញថា មានគេរាំងអ្នកមិនឲ្យដាក់ពាក្យបណ្តឹងសុំសវនាការ ពីព្រោះសាលារៀនមានការបកស្រាយខុស – ដោះស្រាយបណ្តឹងរួចហើយ ឬ បង្ហាញថាសាលារៀនបានលាក់ទុកព័ត៌មានដែលសាលាបានទទួលពីអ្នក។

អ្នក ឬសាលារៀនស្រុកអាចដាក់ពាក្យបណ្តឹងស្នើសុំសវនាការដោយយុត្តិធម[10]ជាលាយលក្ខណ៍អក្សរ ហើយផ្ញើពាក្យបណ្តឹងមួយច្បាប់ មកឲ្យ BSEA ដើម្បីឲ្យទទួលបានសវនាការដោយយុត្តិធម៌ ។ BSEA បានបង្កើតបែបបទស្នើសុំសវនាការ[11] ដែលអ្នកអាចប្រើប្រាស់ ឬអ្នកអាចសរសេរពាក្យបណ្តឹងដោយខ្លួនឯងដោយមិនបាច់ប្រើបែបបទដែលមានស្រាប់នោះទេ។ ក៏ប៉ុន្តែអ្នកត្រូវ ធានាថាក្នុងពាក្យនោះត្រូវមានឈ្មោះសិស្ស អាសយដ្ឋាន (ឬព័ត៌មានសំរាប់ទំនាក់ទំនង ប្រសិនបើសិស្សមិនមានលំនៅឋានពិតប្រាដក) ឈ្មោះសាលារៀនសរសេរបញ្ជាក់ពីបញ្ហាមានរួមទាំងអង្គហេតុជាក់លាក់ដែលទាក់ទងទៅនឹងបញ្ហា និងដំណោះស្រាយដែលចង់បាន។ សូមបញ្ជាក់ថាសវនាការផ្តោតទៅលើបញ្ហាដែលមាននៅក្នុងពាក្យបណ្តឹងនោះទេ។

អ្នកត្រូវផ្ញើពាក្យស្នើសុំសវនាការនោះទៅសាលារៀន (ភាគីដែលពាក់ព័ន្ធក្នុងបណ្តឹង) ហើយផ្ញើមួយច្បាប់ ទៀតទៅ BSEA ។ ប្រសិនបើពាក្យបណ្តឹងមិនផ្តល់ព័ត៌មានគ្រប់គ្រាន់ទេ ភាគីជំទាស់អាចធ្វើការជំទាស់អាចប្រឈម*ភាពគ្រប់គ្រាន់*របស់ខ្លួនក្នុងរយៈពេល 15 ថ្ងៃ ។ ក្នុងរយៈពេល 5 ថ្ងៃ ចាប់ពីថ្ងៃតវ៉ា BSEA នឹងសំរេចថាពាក្យបណ្តឹងនោះមានព័ត៌មានគ្រប់គ្រាន់ ឬ មិនគ្រប់គ្រាន់ ។ បើមានការចាំបាច់ ភាគីពាក់ព័ន្ធអាចសរសេរព័ត៌មានបន្ថែមទៀតទៅក្នុងពាក្យបណ្តឹង ប្រសិនបើភាគីជំទាស់យល់ព្រម ឬ មន្ត្រីសវនាការយល់ព្រម ។ ប្រសិនបើ ព័ត៌មានត្រូវបន្ថែមនៅពេលអនាគតពេលវេលាសវនាការត្រូវលើទៅថ្ងៃក្រោយ។

---

7 http://www.doe.mass.edu/bsea/mediation.html?section=fag

8 http://www.doe.mass.edu/bsea/forms/m_brochure.doc

9 ឃ្លាដែលថា គួរដឹង" រលឹកអ្នកថា អ្នកមានការទទួលខុសត្រូវក្នុងការស្វែងយល់ដឹងអំពីកម្មវិធីសិក្សារបស់កូនអ្នក ។

10 ព័ត៌មានស្តីអំពីសវនាការដោយយុត្តិធម៌មាននៅក្នុងគេហទំព័រ: http://www.doe.mass.edu/bsea/process.html?section=1

11 http://www.doe.mass.edu/bsea/forms/hearing.doc

ប្រសិនបើ មិនមានការជំទាស់ទៅនឹងការខ្វះខាតព័ត៌មានក្នុងពាក្យបណ្ដឹងទេ សវនាការអាចបន្តទៅមុខទៀតបាន។ ប្រសិនបើសាលារៀនស្រុក មិនទាន់ផ្ញើសេចក្ដីជូនដំណឹងមកអ្នកអំពីបញ្ហាដែលអ្នកប្ដឹងជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល 10 ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យបណ្ដឹង ស្នើសុំឲ្យមានសវនាការសាលារៀនស្រុកត្រូវតែធ្វើការឆ្លើយតបមកអ្នកជាលាយលក្ខណ៍អក្សរ ។

**សំគាល់៖** ប្រសិនបើ*សាលារៀនស្រុក* បានស្នើសុំសវនាការដោយយុត្តិធម៌ *ឪពុកម្ដាយ ត្រូវឆ្លើយតប* ក្នុងរយៈពេល 10 ថ្ងៃ បន្ទាប់ពីទទួលលិខិតជូនដំណឹងនោះ ហើយការឆ្លើយតបត្រូវបញ្ជាក់អំពីបញ្ហាដែលសាលារៀនស្រុកបានលើកឡើង។

បន្ទាប់ពីអ្នកដាក់ពាក្យស្នើសុំសវនាការដោយយុត្តិធម៌ សាលារៀនស្រុកត្រូវឆ្លើយតបមកអ្នកវិញក្នុងរយៈពេល 30 ថ្ងៃ ដើម្បីដោះស្រាយភាពមិនចុះសម្រុងគ្នា ឲ្យបានមុនពេលដំណើរការសវនាការចាប់ផ្ដើម[12]។

សាលារៀនស្រុកតម្រូវឲ្យរៀបចំការប្រជុំដោះស្រាយក្នុងរយៈពេល 15 ថ្ងៃបន្ទាប់ពីថ្ងៃទទួលពាក្យបណ្ដឹង[13] សាលារៀនស្រុក នឹងត្រូវពិភាក្សាជាមួយអ្នកថាតើសមាជិកក្រុម IEP ណាម្នាក់នឹងត្រូវចូលរួមប្រជុំ។ បុគ្គលិកសាលារៀនដែលធ្លាប់សំរេចចិត្តអំពីកម្មវិធីអប់រំរបស់សិស្សត្រូវតែចូលរួមក្នុងការប្រជុំនេះកុំបីអាក់ខាន ។ មេធាវីរបស់សាលារៀនមិនអាចចូលរួមប្រជុំទេ ប្រសិនបើមេធាវីអ្នកនឹងចូលរួមក្នុងអង្គប្រជុំនោះ។

អ្នកត្រូវតែចូលរួមប្រជុំដោះស្រាយបញ្ហា លើកលែងតែអ្នក *និង*សាលារៀនស្រុកយល់ព្រមគ្នាជាលាយលក្ខណ៍អក្សរ ថាមិនចាំបាច់រៀបចំការប្រជុំ ឬក៏អ្នក និងសាលារៀនសំរេចយកដំណើរការសម្របសម្រួល។ ប្រសិនបើសាលារៀនស្រុកមិនអាចឲ្យអ្នកចូលរួមប្រជុំបាន សាលារៀននឹងស្នើសុំឲ្យមន្ត្រីសវនាការច្រានចោល ពាក្យបណ្ដឹង។

បើអ្នកមានបំណងចង់ចូលរួមប្រជុំ តែសាលារៀនស្រុកបដិសេធ ឬ ពន្យារពេលនៃការប្រជុំ អស់រយៈពេលជាង 15 ថ្ងៃគិតចាប់ពីថ្ងៃទទួលសេចក្ដីជូនដំណឹងអំពីសវនាការ អ្នកអាចសុំឲ្យមន្ត្រីសវនាការបន្តដំណើរការសវនាការតទៅទៀតបាន។ ប្រសិនបើអ្នកបានចូលរួមប្រជុំ ក៏ប៉ុន្តែសាលារៀនស្រុកមិនបានដោះស្រាយបណ្ដឹងតាមឆន្ទៈរបស់អ្នកក្នុងរយៈពេល 30 ថ្ងៃ ចាប់ពីថ្ងៃដាក់ពាក្យបណ្ដឹង ដូច្នេះដំណើរការនៃសវនាការអាចបន្តទៅមុខទៀត។

ដំណើរការដោះស្រាយត្រូវបញ្ចប់នៅពេលដែលព្រឹត្តិការណ៍ណាមួយដូចខាងក្រោមកើតមានឡើង:

- នៅពេលដែលអ្នកនិងសាលារៀនស្រុកយល់ព្រមជាលាយលក្ខណ៍អក្សរដើម្បីបញ្ចប់អាជ្ញាយុកាលនៃដំណោះស្រាយ;
- រយៈពេល 30 ថ្ងៃសំរាប់ដំណោះស្រាយត្រូវបានបញ្ចប់;
- នៅចុងបញ្ចប់នៃការសម្របសម្រួល; ឬ
- នៅពេលដែលអ្នក និងមន្ត្រីសាលារៀនស្រុកចុះហត្ថលេខាលើឯកសារដែលប្រកាសថាភាគីទាំងពីរយល់ព្រមដោះស្រាយជម្លោះរបស់អ្នក។ នេះជាកិច្ចព្រមព្រៀងដំណោះស្រាយ ហើយនឹងត្រូវអនុវត្តដោយតុលាការសហព័ន្ធ ឬតុលាការរដ្ឋ។ សូមបញ្ជាក់ថា ប្រសិនបើអ្នក និង សាលារៀនស្រុកចាប់ផ្ដើមកិច្ចព្រមព្រៀងដែលជាលទ្ធផលនៃកិច្ចប្រជុំដំណោះស្រាយនោះ អ្នក និងសាលារៀនស្រុកក៏អាចទុកជាមោឃៈចំពោះកិច្ចព្រមព្រៀងនេះក្នុងរយៈពេល 3 ថ្ងៃ នៃថ្ងៃធ្វើការនៅពេលដែលអ្នក និងសាលារៀនស្រុក បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

## 6.5 ការបង្ហាញភស្តុតាងជូនមន្ត្រីសវនាការអព្យាក្រិត្យនៅពេលសវនាការនីតិវិធីត្រឹមត្រូវ

នៅពេលដែលអ្នកដាក់ពាក្យបណ្ដឹងតាមនីតិវិធីត្រឹមត្រូវនោះ BSEA នឹងកំណត់ថ្ងៃសវនាការដោយចាត់តាំងមន្ត្រីសវនាការ និងផ្ញើព័ត៌មានពិស្ដារអំពីដំណើរការសវនាការជូនអ្នក និងបញ្ជីរឈ្មោះមេធាវីដោយមិនគិតកម្រៃ ឬគិតកម្រៃតិចតួច ហើយដែលអ្នកអាចធ្វើទំនាក់ទំនងសុំជំនួយពីអ្នកតស៊ូមតិ។

[12] ប្រសិនបើអ្នក និង សាលារៀនយល់ស្របតាមការសម្របសម្រួល អ្នកនឹងអាចបន្តការសម្របសម្រួលបន្ទាប់ពី 30 ផុតទៅ

[13] មិនមានការប្រជុំដោះស្រាយទេ ប្រសិនសាលារៀនស្នើរសុំឲ្យមានសវនាការយុត្តិធម៌

ក្នុងកំឡុងពេលសវនាការ អ្នក និង សាលារៀនស្រុក នឹងត្រូវបង្ហាញភស្តុតាងនីមួយៗ និងផ្តល់សក្ខីភាពសាក្សីជូនមន្ត្រីសវនាការអព្យាក្រឹត្យដែលអញ្ជើញមកពី BSEA ។ ក្នុងកំឡុងពេលសវនាការនីតិវិធីត្រឹមត្រូវ មានរួមទាំងសវនាការលើនីតិវិធីនៃការដាក់វិន័យ ហើយអ្នកអាចៈ

- ឲ្យមានការអមដំណើរ ផ្តល់យោបល់ ឬ ធ្វើជាតំណាងដោយមេធាវី ឬ អ្នកតស៊ូមតិ
- ឲ្យកូនរបស់អ្នកមានវត្តមាននៅពេលសវនាការ
- សុំឲ្យសវនាការបើកចំហជាសាធារណៈ
- សុំឲ្យបង្ហាញភស្តុតាងដូចជាឯកសារ និងរបាយការណ៍នានា
- ស្នើសុំ ឬតម្រូវឲ្យចេញដីកាកោះហៅសាក្សីឲ្យចូលរួមក្នុងសវនាការ និងឆ្លើយជម្លោះសំណួរ
- សុំមើលភស្តុតាងដែលប្រើប្រាស់ពេលសវនាការក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ មុនសវនាការមកដល់ និងស្នើសុំឲ្យមន្ត្រីសវនាការច្រានចោលភស្តុតាងដែលអ្នកមិនបានឃើញ និង
- ទទួលបានកំណត់ហេតុ និងលទ្ធផលអង្គហេតុសវនាការ និងសេចក្តីសំរេចតាមជំរើសលាយលក្ខណ៍អក្សរ អេឡិចត្រូនិច ដោយឥតគិតថ្លៃ។ ដើម្បីទទួលកំណត់ហេតុសវនាការជាលាយលក្ខណ៍អក្សរ អ្នកត្រូវធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរ ។

ព័ត៌មានបន្ថែមស្តីអំពីសវនាការនេះអាចស្នើសុំពី BSEA តាមទូរសព្ទលេខៈ 617-626-7250 និងអាចបើកមើលតាមគេហទំព័រ http://www.doe.mass.edu/bsea/process។

សវនាការប្រព្រឹត្តទៅតាមច្បាប់[14] នីតិវិធីរដ្ឋបាល Masssachusetts និងគោលការណ៍សវនាការ BSEA[15]។ មន្ត្រីសវនាការត្រូវចេញសេចក្តីសំរេចក្នុងរយៈពេល 45 ថ្ងៃ បន្ទាប់ពីបញ្ចប់នៃអង្គជាយុកាលនៃជម្លោះដូចមានចែងខាងលើ លើកលែងតែមន្ត្រីសវនាការពន្យារពេលបន្ថែមទៀតតាមការស្នើសុំពីភាគីណាមួយ។ មន្ត្រីសវនាការផ្ញើជូនសេចក្តីសំរេចមកអ្នក និងទៅសាលារៀនស្រុកមួយច្បាប់ម្នាក់ ។ មន្ត្រីសវនាការ និងសាលារៀនស្រុកត្រូវគោរពតាមសេចក្តីសំរេចរបស់មន្ត្រីសវនាការ។

សេចក្តីសំរេចរបស់មន្ត្រីសវនាការថាតើកូនរបស់អ្នកមានសិទ្ធិ ឬ មិនមានសិទ្ធិទទួល FAPE ត្រូវផ្អែកលើការរកឃើញសិទ្ធិទទួលការអប់រំពិសេសដែលត្រូវបានគេរំលោភ ឬ ត្រូវបញ្ចប់ដោយសាលារៀនស្រុកដែលបានខកខានមិនអាចបំពេញកាតព្វកិច្ចដល់សិស្សរបស់អ្នក តាមច្បាប់អប់រំពិសេស និងបទបញ្ញានានា។ ប្រសិនបើអ្នកបានដាក់ពាក្យប្តឹងអំពីការរំលោភនីតិវិធីការអប់រំពិសេស (ដូចជាការខកខានមិនរៀបចំប្រជុំក្រុមឲ្យបានត្រឹមត្រូវ ពុំបានរក្សាទុកកំណត់ហេតុឲ្យបានល្អ និងមិនគោរពពេលវេលា) នោះ មន្ត្រីសវនាការអាចរកឃើញថាសិស្សរបស់អ្នកពិតជាមិនបានទទួល FAPE *ប្រសិនបើ* ការខកខានគោរពតាមនីតិវិធី ដូចជាៈ

- ប៉ះពាល់សិទ្ធិរបស់សិស្ស ក្នុងការទទួល FAPE
- ប៉ះពាល់លទ្ធភាពរបស់សិស្សក្នុងការចូលរួមធ្វើសេចក្តីសំរេចអំពីការអប់រំរបស់កូនអ្នក
- មិនឲ្យសិស្សទទួលបានផលប្រយោជន៍ពីការអប់រំ។

សេចក្តីសំរេចរបស់មន្ត្រីសវនាការជាសេចក្តីសំរេចរបស់ស្ថាប័នចុងក្រោយ ហើយមិនអាចធ្វើការពិចារណាជាថ្មីដោយ BSEA ឬ កែប្រែដោយ ESE បានទេ ។ សេចក្តីសំរេចរបស់សវនាការត្រូវជាសាធារណៈ [16] ហើយមាននៅក្នុងគេហទំព័រ http://www.doe.mass.edu/bsea/decisions.html.

## 6.6 បណ្តឹងជំទាស់សេចក្តីសំរេចសវនាការទៅតុលាការសហព័ន្ធ និង តុលាការរដ្ឋ

ភាគីសាលារៀនស្រុក ឬ ឪពុកម្តាយដែលមិនយល់ព្រមសេចក្តីសំរេចរបស់មន្ត្រីសវនាការ ពួកគេអាចធ្វើបណ្តឹងសើរើលើសេចក្តីសំរេចនោះតាមតុលាការរដ្ឋ ឬសហព័ន្ធ ។ បណ្តឹងសើរើនោះត្រូវដាក់ក្នុងរយៈពេល 90 ថ្ងៃបន្ទាប់ពីចេញសេចក្តីសំរេច។

## 6.7 ថ្លៃឈ្នួលមេធាវី

34CFR§300.517

[14] M.G.L.c.30A
[15] http://www.doe.mass.edu/bsea/forms/hearing_rules.doc
[16] សេចក្តីសំរេចរបស់សវនាការត្រូវបោះពុម្ពផ្សាយបន្ទាប់ពីប្រកាសឲ្យមានការផ្ទៀងផ្ទាត់សិស្សរួចរាល់

ភាគីនីមួយៗទទួលខុសត្រូវបង់ថ្លៃឈ្នួលមេធាវីដោយខ្លួនឯង លើកលែងតែតុលាការសំរេចថាមិនឲ្យបង់។ ប្រសិនបើអ្នកទទួលបានលទ្ធផលជាទីគាប់ចិត្តជាលាយលក្ខណ៍អក្សរ ឬក៏ពីសវនាការ ឬពីតុលាការតុលាការ[17] អាចសំរេចថាសាលារៀនស្រុកគួរតែចេញថ្លៃឈ្នួលមេធាវីជំនួសអ្នក។ សូមចំណាំផងដែរថា អ្នកមិនអាចទទួលយកថ្លៃឈ្នួលទាំងនេះសម្រាប់ពេលវេលាដែលបានចំណាយលើការប្តឹងករណីសំណុំរឿងអ្នកឡើយ បន្ទាប់ពីភាគីសាលាសំរេច បានធ្វើការផ្តល់ជូនដំណោះស្រាយ ប្រសិនបើ

- សាលាបានផ្តល់សំណើដោះស្រាយជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 10 ថ្ងៃ ឬ លើសពី 10 ថ្ងៃមុនពេលថ្ងៃសវនាការចាប់ផ្តើម
- អ្នកមិនបានទទួលយកសំណើនោះក្នុងរយៈពេល 10 ថ្ងៃ និង
- លទ្ធផលនៃសវនាការនោះមិនប្រសើរជាងការការផ្តល់ជូនដំណោះស្រាយ។

ប្រសិនបើសាលារៀនស្រុកទទួលបានការសម្រេចចិត្តជាទីពេញចិត្ត តុលាការអាចបញ្ជាឲ្យមេធាវីរបស់អ្នកបង់លើការចំណាយផ្លូវច្បាប់របស់សាលារៀនស្រុកប្រសិនបើតុលាការរកឃើញថាមេធាវីរបស់អ្នកដាក់ពាក្យប្តឹង ឬបន្តប្តឹងបន្ទាប់ពីសិក្សាឃើញថាបណ្តឹង គ្មានមូលដ្ឋានពិត មានហេតុផលឥតបានការ ឬបន្តក្នុងគោលបំណងមិនសមរម្យណាមួយ។ តុលាការក៏អាចបញ្ជាអ្នក ឬមេធាវីបង់ប្រាក់លើការចំណាយផ្លូវច្បាប់ផងដែរប្រសិនបើសំណើរបស់អ្នកសម្រាប់ដំណើរការសវនការ ឬបុព្វហេតុបន្តបន្ទាប់នៃសកម្មភាព ត្រូវបានបង្ហាញក្នុងគោលដៅមិនសមរម្យដូចជាដើម្បីបៀតបៀន ដើម្បីបង្កឲ្យមានការពន្យារពេលមិនចាំបាច់ ឬដើម្បីបង្កើនតម្លៃបណ្តឹងវិវាទ។

## 7. តើអ្នកទទួលខុសត្រូវអ្វីខ្លះប្រសិនបើអ្នកឲ្យសិស្សចូលរៀនសាលាឯកជន និងប្រសិនបើអ្នកគិតថាសាលារៀនស្រុក គួរតែប្រគល់ថ្លៃឈ្នួលបង្រៀនឲ្យមកអ្នកវិញ? 34CFR§300.148

ក្នុងកាលៈទេសៈខ្លះ ឪពុកម្តាយមានជំនឿថា សាលារដ្ឋមិនផ្តល់កម្មវិធី FAPE ដល់សិស្ស ហើយឪពុកម្តាយសំរេចឲ្យកូន ចូលរៀនសាលាឯកជនវិញ។ ឪពុកម្តាយអាចចុះឈ្មោះកូនក្នុងសាលារៀនឯកជនបានដោយចំណាយថវិកាផ្ទាល់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើឪពុកម្តាយជឿជាក់ថា សាលារៀនរដ្ឋគួរតែទទួលខុសត្រូវលើការចំណាយសំរាប់ការសិក្សារបស់សិស្សនៅសាលាឯកជន ឪពុក ម្តាយត្រូវប្រាប់អំពីការជំទាស់របស់ខ្លួនមិនឲ្យកូនរៀនកម្មវិធី IEP និង កម្មវិធីផ្សេងទៀត ត្រូវច្រានចោលកម្មវិធី IEP ហើយត្រូវប្រាប់ទៅសាលាពីគោលបំណងដែលអ្នកដកកូនពីសាលារៀនស្រុកឲ្យទៅ ចុះឈ្មោះចូលរៀននៅសាលាឯកជន ហើយអ្នកត្រូវដាក់ពាក្យស្នើសុំសវនាការមួយដែលរៀបចំឡើងដោយ BSEA ។ ឪពុកម្តាយត្រូវជូនដំណឹងដល់សាលារៀនស្រុកមុនពេលដែលអ្នកដកកូនចេញពីសាលារដ្ឋនៅក្នុងអង្គប្រជុំចុងក្រោយដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 10 ថ្ងៃមុនពេលដកកូនចេញពីសាលា។

សាលារៀនស្រុកមិនអាចតម្រូវឲ្យបង់ថ្លៃសិក្សារបស់កូនក្នុងសាលាឯកជននោះបានទេ ប្រសិនបើសាលារៀនស្រុកមានកម្មវិធី FAPE សំរាប់បង្រៀនកូនរបស់អ្នកដែរនោះ ។ ការមិនចុះសម្រុងគ្នារវាងឪពុកម្តាយ និងសាលារៀនស្រុករបស់អំពីថាតើ កម្មវិធីរបស់សិស្ស ផ្តល់ជូន FAPE ឬអត់ និងការស្នើសុំសំណងហិរញ្ញវត្ថុសម្រាប់តម្លៃកម្មវិធីឯកជនអាចត្រូវបានដោះស្រាយតាមនីតិវិធីយុត្តិធម៌ដូចមានចែងខាងលើក្នុងឯកសារនេះស្រាប់ ។ មន្ត្រីសវនាការ នឹងកំណត់ថាតើសាលារៀនស្រុកបានធ្វើឲ្យកម្មវិធី FAPE អាចដំណើរការបានដល់កូនអ្នកដែរឬទេ។ បើមន្ត្រីសវនាការរកឃើញថា សាលារៀនស្រុក *មិន* បានផ្តល់កម្មវិធី FAPE ដល់កូនអ្នក ហើយចំណាត់ការខាងលើរបស់អ្នក និងការបញ្ជូនកូនឲ្យទៅសិក្សាសាលាឯកជនពិតជាត្រឹមត្រូវនោះ បន្ទាប់ពីមានការពិចារណាគ្រប់កាលៈទេសៈនៃការដកកូនចេញពីសាលារដ្ឋ មន្ត្រីសវនាការអាចតម្រូវឲ្យសាលារៀនស្រុកត្រូវបង់ថ្លៃសិក្សានៅសាលាឯកជនទាំងអស់ ឬ បង់ថ្លៃក្នុងចំណែកណាមួយឲ្យមកអ្នកវិញសម្រាប់ការរកកន្លែងសិក្សានៅសាលាឯកជន។

## 8. តើត្រូវរៀបចំផែនការអ្វីខ្លះសំរាប់បបញ្ជូនកូនអ្នកចេញពីសាលារៀន? 34 CFR §300.43

ការធ្វើផែនការសម្រាប់ការផ្ទេរសិស្សរបស់អ្នកពីសាលារៀនទៅឱកាសរៀនក្រោយពេលបញ្ចប់នៅសាលានឹងជួយសម្របសម្រួលឲ្យសមត្ថភាពសិស្សអ្នកចូលរួមសកម្មភាពនានាដោយជោគជ័យ ដូចជាការសិក្សាក្រោយមធ្យមសិក្សា ការងារ និងសហគមន៍ និងជីវិតមនុស្សពេញវ័យ។ ការរៀបចំផែនការសំរាប់ការបញ្ជូនកូនរបស់អ្នកទៅវិទ្យាល័យត្រូវផ្អែកលើភាពខ្លាំង ការចូលចិត្ត ចំណាប់អារម្មណ៍ និងតម្រូវការនានា ដែលត្រូវចាប់ផ្តើមតាំងពីកូនរបស់អ្នកមានអាយុ 14 ឆ្នាំ ហើយត្រូវមានការពិភាក្សាជារៀងរាល់ឆ្នាំនៅឯកិច្ចប្រជុំក្រុម។ សាលារៀនស្រុកក៏ត្រូវពិភាក្សាអំពីតម្រូវការបញ្ជូនសិស្សរបស់អ្នកជាមួយអ្នក និងជាមួយកូនរបស់អ្នក [18]

[17] មន្ត្រីសវនាការមិនអាចចេញថ្លៃឈ្នួលមេធាវី

[18] http://www.doe.mass.edu/sped/28MR/28m9.doc

ហើយត្រូវតែពិចារណាពីគោលបំណងកូនរបស់អ្នកនៅពេលបញ្ចប់សាលារៀនឌីប្លូម ឬ នៅពេលកូនមានអាយុ 22 ឆ្នាំ ។ សាលារៀនស្រុក ត្រូវប្រើប្រាស់ទម្រង់បែបបទផែនការបញ្ជូន[19] ដើម្បីកត់ត្រាលើការពិភាក្សាប្រចាំឆ្នាំ ។ កម្មវិធី IEP របស់សិស្សត្រូវរួមបញ្ចូល ដូចជាគោលបំណង គោលដៅ និងសេវាកម្មការបញ្ជូនក្រោយមធ្យមសិក្សាដែលអាចវាស់វែងបាន ដោយផ្អែកលើការវាយតម្លៃសមរម្យចំ ពោះពិការភាពរបស់សិស្ស និងតម្រូវការនៃការបញ្ជូនរបស់គាត់។

ការបញ្ចប់សញ្ញាបត្រវិទ្យាល័យតាមពេលទៀងទាត់ គឺជាការផ្លាស់ប្តូរកន្លែងសិក្សា ហើយជាពេលដែលត្រូវបញ្ចប់ភាពមានសិទ្ធិទទួលបានការសិក្សាពិសេស។ សាលារៀនស្រុកត្រូវជូនដំណឹងដល់អ្នក ប្រសិនបើនៅពេលសាលារៀនគិតថាកូនរបស់អ្នកនិងត្រូវបញ្ចប់សញ្ញាបត្រវិទ្យាល័យតាមពេលទៀងទាត់ ។ ការពិភាក្សានេះនឹងត្រូវចាប់ផ្តើមកិច្ចប្រជុំក្រុមដែលមានរយៈពេលមិនតិចជាង 1 ឆ្នាំមុនពេលការបញ្ចប់ការសិក្សារបស់សិស្ស។

## 9. តើសាលារៀនអាចដាក់វិន័យសិស្សពិការដោយវិធីណា? 34 CFR §300.530

សាលារៀនរដ្ឋត្រូវតែមាននីតិវិធី និងបទដ្ឋានដើម្បីធានាឲ្យមានបរិយាសកាសរៀនសូត្រប្រកបដោយសុវត្ថិភាពដល់សិស្ស។ គេរំពឹងថាសាលារៀន និងសាលាវិទ្យាល័យនានា ត្រូវបោះពុម្ពផ្សាយក្រមសីលធម៌ដើម្បីឲ្យសិស្សយល់ដឹងថាតើ គេត្រូវធ្វើអាកប្បកិរិយាដោយវិធីណា។ ប្រសិនបើសិស្សប្រព្រឹត្តិខុស ហើយរំលោភក្រមសីលធម៌របស់សាលា សាលាអាចដាក់ពិន័យសិស្សនោះបាន ។ ការដាក់វិន័យត្រូវធ្វើឡើងប្រកបដោយយុត្តិធម៌ និងអព្យាក្រឹត្យ ។

ជាទូទៅ សិស្សម្នាក់ៗអាចប្រឈមនឹងការដាក់វិន័យដូចជា ការផ្អាកការសិក្សា ឬ ឲ្យចេញពីសាលារៀនក្នុងរយៈពេលខ្លី ហើយរយៈពេលនោះមិនត្រូវហួសពី 10 ថ្ងៃឡើយ។ មុនពេល ឲ្យចេញពីសាលា និងផ្អាកការសិក្សាសិស្សម្នាក់ៗ ត្រូវដឹងថាតើខ្លួនទទួលរងការចោទប្រកាន់អ្វីខ្លះ ហើយត្រូវមានឱកាសសំរាប់រៀបរាប់រឿងរបស់ខ្លួន។ ក្នុងកំឡុងពេលបណ្តេញចេញពីសាលារៀន រយៈពេលខ្លី សាលារៀនមិនតម្រូវឲ្យផ្តល់ការណែនាំដល់សិស្សពិការទេ ចំពោះសិស្សធម្មតាត្រូវមានការណែនាំ។ សរុបមក បើសិស្សពិការត្រូវបានដេញពីសាលារៀនមានរយៈពេល 10 ថ្ងៃក្នុងមួយឆ្នាំសិក្សា សិស្សនោះត្រូវអនុញ្ញាតឲ្យទទួលសេវាកម្មចូលរៀនក្នុងកម្មវិធីសិក្សាទូទៅជាបន្ត ហើយធ្វើឲ្យសិស្សនោះនឹងសំរេចគោលដៅដែលមានចែងក្នុង IEP ។ មន្ត្រីរបស់សាលាត្រូវពិគ្រោះយោបល់ជាមួយគ្រូរបស់សិស្សឲ្យបានម្នាក់យ៉ាងតិច ដើម្បីកំណត់ថាតើសេវាកម្មអ្វីខ្លះ ដែលវាចាំបាច់ត្រូវតែផ្តល់ឲ្យសិស្សនោះ។ សេវាកម្មទាំងអស់នេះត្រូវចាប់ផ្តើមនៅថ្ងៃទី 11 នៃការដាក់ពិន័យឲ្យចេញពីសាលា និងសេវាកម្មត្រូវផ្តល់ជាបន្តទៀតនៅពេលដែលការដាក់ពិន័យត្រូវបញ្ចប់ ។

សាលារៀននានា ត្រូវអនុវត្តតាមបទបញ្ជាវិន័យពិសេសសំរាប់សិស្សពិការដែលមានសិស្សទទួលបានការអប់រំពិសេស។[20] តារាងសំរាប់ការដាក់ពិន័យនេះមានចុះផ្សាយនៅក្នុងគេហទំព័ររបស់ ESE ។[21] បទបញ្ជាដាក់ពិន័យនេះត្រូវអនុវត្តភ្លាមៗ សំរាប់សិស្សណាម្នាក់ដែលត្រូវបានបណ្តេញចេញកន្លែងដែលកំពុងតែសិក្សា[22] អស់រយៈពេលជាង 11 ថ្ងៃជាប់គ្នា ឬ ក៏សិស្សនោះត្រូវបាន គេបណ្តេញដោយសារការដាក់ពិន័យជាង 11 ថ្ងៃក្នុងមួយឆ្នាំសិក្សា ហើយមានឯកសារសំរាប់ ប្រៀបធៀបផ្ទៀងផ្ទាត់មើលមូលហេតុនៃការបណ្តេញចេញ។ សាលារៀនត្រូវជូនដំណឹងដល់អ្នកជាបន្ទាន់នៅពេលសាលាធ្វើ សេចក្តីសំរេចបណ្តេញសិស្សចេញពីកន្លែងសិក្សាដែលមានរយៈពេល 10 ថ្ងៃ ហើយសាលាប្រគល់សេចក្តីជូនដំណឹងមួយ ច្បាប់នោះឲ្យអ្នក។

ក្រុមកម្មវិធី IEP របស់សិស្សត្រូវធ្វើការប្រជុំក្នុងរយៈពេល 10 ថ្ងៃចាប់ពីថ្ងៃដែលធ្វើសេចក្តីសំរេចការដាក់ពិន័យដល់សិស្ស ។ ប្រជុំនេះហៅថា *"ការកំណត់បង្ហាញអង្គហេតុ manifestation determination"* អ្នក និងសមាជិកផ្សេងទៀតរបស់ក្រុម IEP នឹងត្រូវកំណត់ថាតើ ការប្រព្រឹត្តិខុសរបស់សិស្សបណ្តាលមកពីពិការភាពរបស់សិស្សនោះដែរទេឬក៏វាជាលទ្ធផលដែលបណ្តាលមកពីសាលាមិនបានផ្តល់សេវាកម្មដែលមាននៅក្នុងកម្មវិធី IEP ដល់សិស្ស ។ នៅក្នុងការកំណត់បង្ហាញអង្គហេតុនោះ អ្នកនឹងសមាជិករបស់ក្រុម IEP ត្រូវពិចារណាលើព័ត៌មានដែលពាក់ព័ន្ធទៅនឹងជីវិតរបស់សិស្សដែលមានរួមបញ្ចូល ដូចជា កម្មវិធី IEP –ការសង្កេតរបស់អ្នក និងរបស់គ្រូលើអាកប្បកិរិយារបស់សិស្ស និងព័ត៌មានផ្សេងទៀតដែលអ្នកផ្តល់ជូនក្នុងអង្គប្រជុំ។

---

[19] http://www.doe.mass.edu/sped/28MR/28m9.doc

[20] ច្បាប់ដាក់វិន័យក្នុងកម្មវិធីសិក្សាអប់រំពិសេស ក៏ត្រូវអនុវត្តសំរាប់សិស្សណាដែលមិនទាន់មានសិទ្ធិទទួលការអប់រំពិសេសនោះផងដែរ។ មុនពេល ធ្វើការសួរ ប្រសិនបើឪពុកម្តាយលើកយកការព្រួយបារម្ភរបស់សិស្សជាលាយលក្ខណ៍អក្សរទៅជូនថ្នាក់លើ ឬ បុគ្គលិករដ្ឋបាល ឬគ្រូរបស់សិស្ស នោះថាសិស្សនោះប្រហែលជានឹងអាចមានពិការភាព ប្រសិនបើគ្រូ ឬបុគ្គលិកផ្សេងៗទៀតសំដែងការព្រួយបារម្ភអំពីអាកប្បកិរិយារបស់សិស្ស ជំរាបជូនទៅនាយកនៃកម្មវិធីអប់រំពិសេសនោះ ឬបុគ្គលិកគ្រប់គ្រងផ្សេងទៀត ប្រសិនបើសិស្សត្រូវបានគេយកទៅធ្វើការវាយតម្លៃមិនទាន់ចប់សព្វគ្រប់បទបញ្ជាវិន័យ ពិសេសនេះត្រូវយកមកអនុវត្តបានដែរ។ បទបញ្ជាពិន័យពិសេសនេះមិនអាចអនុវត្តទេ ប្រសិនបើឪពុកម្តាយបដិសេធមិនយល់ព្រមឲ្យមានការវាយតម្លៃ ឬ សិស្សធ្លាប់ត្រូវបានគេរកឃើញថាសិស្សនោះមិនមានសិទ្ធិទទួលបានការអប់រំពិសេសទេ។

[21] http://www.doe.mass.edu/sped/IDEA2004/spr_meetings/disc_chart.doc

[22] ជាកន្លែងសិក្សាដែលកំណត់ដោយក្រុម IEP និង ជាកន្លែងដែលទទួលសេវាកម្មពីIEP

ប្រសិនបើក្រុមការងារកំណត់ថា អកប្បកិរិយារបស់សិស្ស មិនបណ្ដាលមកពី ឬទាក់ទងផ្ទាល់ទៅនឹងពិការភាព ឬ មិនទាក់ទងទៅនឹងការខកខានមិនអនុវត្តកម្មវិធី IEP ទេ សិស្សដែលមានពិការភាពអាចត្រូវដាក់វិន័យដែលមានលក្ខណៈ និង រយៈពេលដូចការដាក់ពិន័យសិស្សផ្សេងទៀតដែលប្រព្រឹត្តិកំហុសដូចគ្នា។ ទោះបីជាយ៉ាងណាក៏ដោយក្រុម IEP ត្រូវកំណត់កន្លែងសិក្សាបណ្ដោះអាសន្នសំរាប់សិស្ស (Interim Alternative Educational Setting-IAES) ដើម្បីឲ្យសិស្សបានសិក្សា និង ទទួលសេវាកម្មផ្សេងៗទៀតក្នុងកំឡុងពេលនៃការដាក់ពិន័យ ។ IAES គឺជាកន្លែងរៀបចំថ្មី ដើម្បីឲ្យសិស្សមានឱកាសរៀន និង ទទួលសេវាកម្មអប់រំជាបន្តដោយយោងទៅតាមកម្មវិធី IEPរបស់សិស្ស ។ បុគ្គលិករបស់សាលាពិចារណាលើកាលៈទេសៈនៃការប្ដូរកន្លែងសិក្សាសំរាប់សិស្សពិការវាជាការសមរម្យឬយ៉ាងណា។

ប្រសិនបើក្រុមកំណត់រកឃើញថាអាកប្បកិរិយារបស់សិស្សបណ្ដាលមកពី ឬទាក់ទងទៅផ្ទាល់ទៅនឹងពិការភាព ឬការខកខានមិនអនុវត្តកម្មវិធី IEP ត្រឹមត្រូវសំរាប់សិស្សដែលមានពិការភាព ដូច្នេះសិស្សត្រូវបញ្ជូនទៅកន្លែងដើមដែលមានកម្មវិធី IEP លើកលែងតែអ្នក និងក្រុមការងារសំរេចឲ្យទៅរៀនកន្លែងផ្សេងវិញ។ សិស្សត្រូវតែទទួលបានព័ត៌មាន ស្ដីពីការវាយតម្លៃអំពីអាកប្បកិរិយារបស់ខ្លួន។ ការវាយតម្លអាកប្បកិរិយារបស់សិស្សនោះ ឬ FBA គឺជាការវាយតម្លៃទូទៅផ្ដល់ព័ត៌មានអំពីអត្តចរិកសិស្សជូនដល់ក្រុម IEP និង អំពីសេវាកម្មអន្តរាគមន៍ផ្នែកអាកប្បកិរិយា និងកម្មវិធីកែប្រែដែលត្រូវរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងអាកប្បកិរិយាហឹង្សាកុំឲ្យវាកើតឡើងពេលក្រោយទៀត។ ប្រសិនបើសិស្សបានទទួលការវាយតម្លៃអាកប្បកិរិយារួច និង ទទួលការអប់រំខាងផ្នែកអន្តរាគមន៍អាកប្បកិរិយាក្រុម IEP ត្រូវពិចារណាលើការកែប្រែផែនការអន្តរាគមន៍អាកប្បកិរិយាឲ្យបានល្អ ។ ប្រសិនបើអាកប្បកិរិយា នោះបណ្ដាលមកពីការបរាជ័យមិនបានអនុវត្តកម្មវិធី IEP ឲ្យបានត្រឹមត្រូវទេ សាលារៀនត្រូវចាត់វិធានការដោះស្រាយដើម្បីធ្វើឲ្យកម្មវិធីនោះមានប្រសិទ្ធភាពភ្លាមៗ។

សូមចំណាំថា ប្រសិនបើសិស្សមាន ឬប្រើប្រាស់អាវុធ ថ្នាំញៀន ឬបណ្ដាលឲ្យមានរបួលលើរាងកាយអ្នកដ៏ទៃនៅក្នុងបរិវេណសាលា ឬ នៅក្នុងព្រឹត្តិការណ៍សាលា នាយកសាលាត្រូវបញ្ជូនសិស្សនោះឲ្យទៅសិក្សានៅកន្លែងកម្មវិធីអប់រំបណ្ដោះអាសន្នរហូតដល់ 45 ថ្ងៃនៃថ្ងៃសិក្សាដោយមិនបាច់គិតអំពីការកំណត់អំពីពិការភាពរបស់សិស្សឡើយ។ ក្រុម IEP នឹងកំណត់ ថាតើត្រូវមានការផ្ដល់កម្មវិធីអប់រំបណ្ដោះអាសន្ន IAES និង សេវាកម្មអប់រំសមរម្យដល់សិស្សដែលគេបញ្ជូនទៅកន្លែងអប់រំបណ្ដោះអាសន្ន IAES ទេ។

### 9.1 ការប្ដឹងជំទាស់នឹងសេចក្ដីសំរេចដាក់វិន័យ

ប្រសិនបើឪពុកម្ដាយមិនយល់ព្រមចំពោះសេចក្ដីសំរេចក្នុងការប្ដូរកន្លែងសិក្សាដោយសារការដាក់ពិន័យ ឬ មិនយល់ព្រមការកំណត់បង្ហាញអង្គហេតុ ឬក៏សាលាជឿជាក់ថា ការអនុញ្ញាតឲ្យសិស្សនៅរៀនកន្លែងដ៏ដែលទំនងជាធ្វើឲ្យសិស្សផ្សេងៗរងរបួសនោះ ឪពុកម្ដាយ ឬ សាលារៀនអាចប្ដឹងជំទាស់នឹងសេចក្ដីសំរេចនោះដោយស្នើសុំសវនាការជាមួយ BSEA ដូចដែលមានចែងខាងលើក្នុងឯកសារនេះស្រាប់។

BSEA នឹងរៀបចំសវនាការមួយស្ដីអំពីការដាក់វិន័យ ឬការកំណត់បង្ហាញអង្គហេតុដោយរស់រាន់[23] ។ ក្នុងកំឡុងពេលប្ដឹងជំទាស់ទៅនឹងការដាក់ពិន័យការកំណត់បង្ហាញអង្គហេតុសិស្សត្រូវស្ថិតនៅក្នុងកម្មវិធី IAES រហូតដល់មន្ត្រីសវនាការធ្វើសេចក្ដីសំរេច ឬរយៈពេលនៃការដាក់វិន័យត្រូវបញ្ចប់ ឬក៏ឪពុកម្ដាយ និងសាលារៀនស្រុកព្រមព្រៀងគ្នាលើការផ្លាស់ប្ដូរកន្លែងសិក្សា។

## 10. តើអាចស្វែងរកច្បាប់ បទបញ្ញា និង ព័ត៌មានសំខាន់ៗនៅកន្លែងណា?

### 10.1 ច្បាប់ និង បទបញ្ញា

អ្នកអាចស្វែងរកអត្ថបទច្បាប់ស្ដីអំពីការអប់រំពិសេសរបស់រដ្ឋនៅក្នុងច្បាប់ទូទៅរបស់រដ្ឋ Massachusetts 71B។ ច្បាប់របស់រដ្ឋនេះ ត្រូវបានគេស្គាល់ថាជំពូក "Chapter 766" ។ បទបញ្ញាអប់រំពិសេស អាចរកឃើញនៅក្នុងក្រមនៃបបទបញ្ញា Massachusetts (CMR) 603CMR28.00. ច្បាប់និងបទបញ្ញា ព្រមទាំងព័ត៌មានផ្សេងៗទៀតមាននៅក្នុងគេហទំព័រ ESE។[24]

ច្បាប់អប់រំពិសេសរបស់សហព័ន្ធ គឺជាច្បាប់អប់រំសំរាប់បុគ្គលដែលមានពិការភាព Disabilities Education Act ដែលគេស្គាល់ថា "IDEA"។ ល័ក្ខន្តិកៈ សហព័ន្ធ មាននៅក្នុងក្រមរបស់សហរដ្ឋ 20U.S.C §1400។ បទបញ្ញាអនុវត្តសំរាប់ IDEA អាចមាននៅ

[23] សូមមើលច្បាប់សវនាការ BSEA II.C. http://www.doe.mass.edu/bsea/forms/hearing_rules.doc p.6

[24] http://www.doe.mass.edu/sped/laws.html

ក្នុងក្រមបទបញ្ញាសហព័ន្ធ Code of Federal Regulations (CFR) ជំពូកទី 34 ផ្នែក 300។ ព័ត៌មានពិស្តារអំពីច្បាប់ បទបញ្ញា មាននៅក្នុងគេហទំព័រនៃក្រសួងអប់រំរបស់សហរដ្ឋអាមេរិក U.S. Department of Education គឺ http://idea.ed.gov ។

## 10.2 គោលការណ៍ណែនាំដំណើរការកម្មវិធីអប់រំឯកជន និងទម្រង់បែបបទផ្សេងៗ

ការពិនិត្យមើលជាទូទៅមួយអំពីថាតើ ដំណើរការអប់រំពិសេសប្រព្រឹត្តទៅដូចម្តេច (ដកស្រង់ពីគោលការណ៍ណែនាំកម្មវិធី IEP ដែលរៀបចំដោយ USDOE) មាននៅក្នុងគេហទំព័រ : htt;://www.doe..mass.edu/sped/iep

សម្រាប់ការពន្យល់ ESE ថាតើកម្មវិធី IEP ត្រូវបានអភិវឌ្ឍន៍យ៉ាងដូចម្តេច សូមប្រឹក្សាយោបល់ការណែនាំដំណើរការកម្មវិធី IEP និងទម្រង់បែបបទកម្មវិធី IEP ស្តង់ដារដែលអាចមាននៅលើវែបសាយ៖ http://www.doe.mass.edu/sped/iep ។

## 10.3 តារាងអក្សរកាត់

មានឃ្លាជាច្រើនត្រូវគេសរសេរជាអក្សរកាត់។ ដើម្បីធ្វើឲ្យងាយស្រួលចំណាំខាងក្រោមនេះគឺជាអក្សរកាត់ដែលមាននៅក្នុងឯកសារនេះ។

BSEA: Bureau of Special Education Appeals ការិយាល័យតវ៉ាផ្នែកអប់រំពិសេស

CFR: Code of Feral Regulations ក្រមបទបញ្ញាសហព័ន្ធ

CMR: Code of Massachusetts Regulation ក្រមបទបញ្ញាសហព័ន្ធរដ្ឋ Massachusetts

ESE: Massachusetts Department of Elementary and Secondary Education មន្ទីរអប់រំបឋមសិក្សា និងអនុវិទ្យាល័ Massachusetts

FAPE: Free Appropriate Public Education ការអប់រំសាធារណៈដោយឥតគិតថ្លៃ

FBA: Functional Behavioral Assessment ការវាយតម្លៃអាកប្បកិរិយា

IAES: Interim Alternative Education Setting កន្លែងសិក្សាបណ្តោះអាសន្ន

IDEA: Individuals with Disabilities Education Act បុគ្គលនានាដែលមានច្បាប់អប់រំមនុស្សពិការ

IEE: Independent Educational Evaluation ការវាយតម្លៃការអប់រំដោយឯករាជ្យ

IEP: Individualized Education Program កម្មវិធីអប់រំលក្ខណៈបុគ្គល

PQA: Program Quality Assurance Services កម្មវិធីសេវាកម្មធានាគុណភាព

## 10.4 តារាងគេហទំព័រ

ការអប់រំថ្នាក់បឋម និងមធ្យម ESE ផ្សព្វផ្សាយព័ត៌មានទូលំទូលាយដល់មាតាបិតាសិស្ស និងសាលារៀនស្រុកស្តីអំពីគេហទំព័ររបស់ខ្លួន។ គេហទំព័រទាំងនេះរួមមាន ច្បាប់ដែលពាក់ព័ន្ធនឹងបញ្ហាកំពុងប្រឈម គោលនយោបាយទីភ្នាក់ងារ និងឯកសារ មានប្រយោជន៍ដែលពន្យល់អំពីដំណើការនៃការអប់រំពិសេស។

ការិយាល័យតវ៉ាអប់រំពិសេស៖
http://www.doe.mass.edu/sped/advisories/07_1ta.html

ការិយាល័យតវ៉ាផ្នែកអប់រំពិសេស
http://www.doe.mass.edu/bsea/decisions.html

http://www.doe.mass.edu/bsea/decisions.html
http://www.mass.gov/anf/docs/dala/bsea/hearing-rules.doc
http://www.mass.gov/anf/docs/dala/bsea/hearing.doc
http://www.mass.gov/anf/hearings-and-appeals/bureau-of-special-education-appeals-bsea/mediation/
http://www.mass.gov/anf/docs/dala/bsea/mediation-brochure-2012.doc

http://www.mass.gov/anf/hearings-and-appeals/bureau-of-special-education-appeals-bsea/mediation/mediation-faqs.html
http://www.mass.gov/anf/docs/dala/bsea/

ការព្រមព្រៀងចំពោះការប្រើកម្មវិធី MassHealth (Medicaid):
http://www.doe.mass.edu/sped/advisories/13_1.html
http://www.doe.mass.edu/sped/28mr/28m13.pdf (ទម្រង់បែបបទលិខិតប្រគល់សិទ្ធិ 28M/13)

វិន័យ៖
http://www.doe.mass.edu/sped/IDEA2004/spr_meetings/disc_chart.do
បុគ្គលនានាដែលមានច្បាប់ស្តីពីអប់រំមនុស្សពិការ៖
http://www.idea.ed.gov/
ដំណើការនៃការអប់រំពិសេសក្រោម IDEA៖
http://www.doe.mass.edu/sped/iep/process.doc
កម្មវិធីអប់រំលក្ខណ:បុគ្គល៖
http://www.doe.mass.edu/sped/iep
សេចក្តីណែនាំស្តីពីដំណើរការកម្មវិធីអប់រំសម្រាប់បុគ្គល៖
http://www.doe.mass.edu/sped/iep/proguide.pdf
ការវាយតម្លៃការអប់រំឯករាជ្យ៖
http://www.doe.mass.edu/sped/advisories/?section=admin
ការសង្កេត**អំពី**កម្មវិធីអប់រំដោយមាតាបិតាសិស្ស និងអ្នកបង្ហាញសម្រាប់គោលបំណងវាយតម្លៃ៖
http://www.doe.mass.edu/sped/advisories/09_2.html
សេចក្តីជូនដំណឹងដល់មាតាបិតាស្តីអំពីការការពារតាមនីតិវិធី៖
http://www.doe.mass.edu/sped/prb
ប្រព័ន្ធដំណោះស្រាយបញ្ហា PQA ដែលប្រៀបធៀបការតវ៉ាអំពីនីតិវិធីត្រឹមត្រូវ BSEA ៖
http://www.doe.mass.edu/sped/complaintchart.doc
កម្មវិធីប្រព័ន្ធដោះស្រាយបញ្ហាកម្មវិធីសេវាកម្មដែលធានាគុណភាព
http://www.doe.mass.edu/pqa/prs
បទបញ្ញា និងច្បាប់ស្តីពីអប់រំពិសេស
http://www.doe.mass.edu/sped/law/html
អ្នកតំណាងឪពុកឬម្តាយផ្នែកអប់រំពិសេស៖
http://www.doe.mass.edu/sped/2002/news/1104memo.html
បែបបទរៀបចំផែនអប់រំសំរាប់ការផ្ទេរការអប់រំពិសេស៖
http://www.doe.mass.edu/sped/28MR/28m9.doc
បទបញ្ញាកំណត់ហេតុសិស្ស៖
http://www.doe.mass.edu/lawregs/603cmr23.html
សំណួរនិងចម្លើយអំពីកំណត់ហេតុសិស្ស៖
http://www.doe.mass.edu/lawsregs/advisory/cmr23ganda.html?section
ការផែនការផ្ទេរសាលា៖
http://www.doe.mass.edu/sped/cspd/mod4.html#